


វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា


# ពាណិជ្ជកម្មកសិកម្ម ក្នុងមហាអនុតំបន់មេគង្គៈ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា


ឯកសារពិភាក្សាលេខ ៤៣



ហ៊ីង វុត្ថា និង បណ្ឌិត ផន់ វឌ្ឍនា



បណ្តាញវិភាគអភិវឌ្ឍន៍ (DAN) បានទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ ROCKEFELLER

# ពាណិជ្ជកម្មកសិកម្ម
# ក្នុងមហាអនុតំបន់មេគង្គ:
# ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា

ឯកសារពិភាក្សាលេខ ៤៣

ដោយ ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ខែមករា ២០១០

© រក្សាសិទ្ធិឆ្នាំ២០១០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជាឡើយ ។

ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់ វិទ្យាស្ថាន CDRI ទេ ។

ISBN 978–99950–52-30-0

**ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គៈ ករណីដំឡូងឈើ និងគោស៊ូ នៅកម្ពុជា**
**ខែមករា ២០១០**

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
អាគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ:(៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@wicam.com.kh website: http://www.cdri.org.kh

បកប្រែដោយ: លោក ទា សាវ៉ា
កែសម្រួល និងរចនាដោយ: អ្នកស្រី ម៉េន-ច័ន្ទធីតា លោក អ៊ុំ-ចាន់ថា និងលោក យូ សិទ្ធិរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន រាជធានីភ្នំពេញ

# មាតិកា

បញ្ជីអក្សរកាត់............ ៧
បញ្ជីតារាង និងក្រាហ្វិក............ ៩
សេចក្តីថ្លែងអំណរគុណ............ ១១

**ជំពូកទី ១. សេចក្តីផ្តើម............ ១៣**

**ជំពូកទី ២. វិធីសាស្ត្រ............ ១៥**

**ជំពូកទី ៣. ផលិតកម្ម............ ១៧**

៣.១. ដំឡូងឈើ............ ១៧
៣.១.១. ទិដ្ឋភាពទូទៅនៃផលិតកម្មដំឡូងឈើ............ ១៧
៣.១.២. របៀបរបបដាំដុះ............ ១៨
៣.១.៣. ចំណាយផលិតកម្ម............ ២០
៣.១.៤ បញ្ហាប្រឈម និងឱកាសល្អ............ ២២
៣.២. កៅស៊ូ............ ២៣
៣.២.១ ទិដ្ឋភាពទូទៅនៃផលិតកម្មកៅស៊ូ............ ២៣
៣.២.២. របៀបរបបដាំដុះ............ ២៥
៣.២.៣. ចំណាយផលិតកម្ម............ ២៧
៣.២.៤ សក្តានុពល និងគោលនយោបាយ............ ២៩
៣.២.៥. ឧបសគ្គ និងឱកាស............ ២៩

**ជំពូកទី ៤. ពាណិជ្ជកម្ម............ ៣១**

៤.១. ពាណិជ្ជកម្មដំឡូងឈើ............ ៣១
៤.១.១. ខ្សែរយៈទីផ្សារ............ ៣១
៤.១.២ ចំណាយ និងចំណេញ............ ៣៤
៤.១.៣. បញ្ហាប្រឈម និងឱកាសល្អ............ ៣៧
៤.២. ពាណិជ្ជកម្មកៅស៊ូ............ ៣៨
៤.២.១. ខ្សែរយៈទីផ្សារ............ ៣៨
៤.២.២. ការកែច្នៃ............ ៣៩
៤.២.៣. ចំណាយ និងចំណេញ............ ៤០

៤.២.៤. ឧបសគ្គ និងឱកាសល្អ ........ ៤១

**ជំពូកទី ៥. អនុសាសន៍ផ្នែកគោលនយោបាយ និងសេចក្តីសន្និដ្ឋាន ........ ៤៣**

៥.១. សំរាប់ដំឡូងឈើ ........ ៤៣
៥.២. សំរាប់ដំឡូងឈើ ........ ៤៥

ឯកសារយោង ........ ៤៩

ឧបសម្ព័ន្ធ ........ ៥១

បញ្ជីឯកសារពិភាក្សារបស់ វិបសអ ........ ៦៥

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ACFTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ASEAN-China Free Trade Agreement) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (ASEAN Development Bank) |
| AFTA-CEPT | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-តារាងអនុគ្រោះពន្ធគយមានប្រសិទ្ធភាពរួម (ASEAN Free Trade Area-Common Effective Preferential Tariff) |
| ASEAN | អាស៊ាន (សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍: Association of Southeast Asian Nations) |
| AFD | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (Agence Francaise de Development) |
| DRC | ចំណុះជ័រកៅស៊ូស្ងួត (Dry Rubber Content) |
| DTIS | ការសិក្សាពីស្ថានភាពសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (Diagnostic Trade Integration Study) |
| FAO | អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (Food and Agriculture Organization) |
| EHP | កម្មវិធីប្រមូលផលដើមដៃ (Early Harvest Program) |
| IRA | សមាគមកៅស៊ូអន្តរជាតិ (International Rubber Association) |
| GMS | មហាអនុតំបន់មេគង្គ (Greater Mekong Sub-region) |
| GSP | ប្រព័ន្ធអនុគ្រោះទូទៅ (Generalized System of Preferences) |
| GVA | តម្លៃបន្ថែមដុល (Gross Value Added) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| IRRDB | ក្រុមប្រឹក្សាអភិវឌ្ឍន៍ និងស្រាវជ្រាវកៅស៊ូអន្តរជាតិ (International Rubber Research and Development Board) |
| LDC | ប្រទេសលូតលាស់តិចជាងគេ (Least Developed Country) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MoC | ក្រសួងពាណិជ្ជកម្ម (Ministry of Commerce) |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (National Strategic Development Plan) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| RRIC | វិទ្យាស្ថានស្រាវជ្រាវដំណាំកៅស៊ូនៅកម្ពុជា (Rubber Research Institute of Cambodia) |
| SEDP | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច (Socio-Economic Development Plan) |
| SPS | អនាម័យ និងភូតគាមអនាម័យ (Sanitary and Phytosanitary) |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Programme) |
| VAT | អាករលើតម្លៃបន្ថែម (Value Added Tax) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization) |
| ផសស | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product-GDP) |
| គ.ក្រ | គីឡូក្រាម |

# បញ្ជីក្រាហ្វិក និងតារាង

## បញ្ជីក្រាហ្វិក


ក្រាហ្វិក ២.១: ផែនទីបង្ហាញទីតាំងភូមិសាស្ត្រនៃការសិក្សា.......... ១៥

ក្រាហ្វិក ៣.១: ផលិតកម្មដំឡូងឈើនៅកម្ពុជា.......... ១៧
ក្រាហ្វិក ៣.២: ដំណើរការ និងពេលវេលាដាំដុះដំឡូងឈើ.......... ១៩

ក្រាហ្វិក ៤.១: គំនូសបំព្រួញនៃពាណិជ្ជកម្មដំឡូងឈើ.......... ៣១
ក្រាហ្វិក ៤.២: គំនូសបំព្រួញផលិតផលកៅស៊ូនៅកម្ពុជា.......... ៣៨


## បញ្ជីតារាង


តារាង ៣.១: ផលិតកម្មដំឡូងឈើនៅតាមខេត្តមួយចំនួននៅឆ្នាំ ២០០១ និង ២០០៥.......... ១៨
តារាង ៣.២: ចំណាយផលិតកម្មដំឡូងឈើនៅស្រុកកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧.......... ២០
តារាង ៣.៣: ចំណាយផលិតកម្មដំឡូងឈើនៅស្រុកមេមត់ ខេត្តកំពង់ចាម ឆ្នាំ២០០៧.......... ២២
តារាង ៣.៤: កម្មសិទ្ធិគ្រួសារលើដីដាំកៅស៊ូ.......... ២៤
តារាង ៣.៥: ប្រភេទពូជកៅស៊ូកំពុងប្រើ.......... ២៦
តារាង ៣.៦: ចំណាយផលិតកម្មកៅស៊ូនៅមេមត់ និងពញាក្រែក ឆ្នាំ២០០៧.......... ២៨

តារាង ៤.១: ចំណូលដុលពីការលក់ដំឡូងឈើនៅស្រុកកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧.......... ៣២
តារាង ៤.២: ចំណូលដុលពីការលក់ដំឡូងឈើនៅខេត្តកំពង់ចាម ឆ្នាំ២០០៧.......... ៣៣
តារាង ៤.៣: ប្រាក់ចំណេញរបស់ឈ្មួញក្នុងស្រុកនៅស្រុកកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧.......... ៣៤
តារាង ៤.៤: កម្រិតប្រាក់ចំណេញពីដំណាំដំឡូងឈើនៅកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧.......... ៣៥
តារាង ៤.៥: កម្រិតប្រាក់ចំណេញពីដំណាំដំឡូងឈើនៅមេមត់ ខេត្តកំពង់ចាម ឆ្នាំ២០០៧.......... ៣៦
តារាង ៤.៦: ទីផ្សារកៅស៊ូសំរាប់កសិករ.......... ៣៩

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ អស់លោក លោកស្រីទាំងអស់ដែលបានចូលរួមចំណែកផ្តល់ទិន្នន័យ និងគាំទ្រដល់ការសិក្សានេះ ជាពិសេសដល់រដ្ឋបាលមូលដ្ឋានក្នុងខេត្តបាត់ដំបង និងខេត្តកំពង់ចាម ក៏ដូចជាអ្នកភូមិដែលបានចូលរួមផ្តល់សម្ភាសន៍ និងជួយសហការក្នុងអំឡុងពេលប្រមូលទិន្នន័យ ។ ការចូលរួមចំណែកនេះ មានតម្លៃថ្លៃថ្លាបំផុតសម្រាប់ការសិក្សារបស់យើងខ្ញុំ ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ បណ្ឌិត ធន់ វឌ្ឍនា ដែលបានចូលរួមចំណែកក្នុងការសរសេរឯកសារស្រាវជ្រាវនេះ ជាពិសេសក្នុងជំពូកស្តីពីដំណាំកៅស៊ូ និង បណ្ឌិត Hossein Jalilian ដែលបានផ្តល់យោបល់លើទិដ្ឋភាពទូទៅ និងលក្ខណៈបច្ចេកទេសនៃរបាយការណ៍នេះ និងជាពិសេសចំពោះ អ្នកស្រី ឆាយ ពិដោរ និងអ្នកចុះធ្វើសម្ភាសន៍ដទៃទៀត ដែលបានពុះពារបំពេញការងារនៅតាមមូលដ្ឋាន ។

អ្នកនិពន្ធសូមសំដែងនូវអំណរគុណជាពិសេសដល់មូលនិធិ Rockefeller Foundation ដែលបានផ្តល់មូលនិធិទ្រទ្រង់ដ៏សប្បុរសដល់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងបណ្តាញវិភាគអភិវឌ្ឍន៍ ញ៉ាំងឱ្យការសិក្សានេះអាចដំណើរការទៅមុខបាន ។

*ហ៊ីង វុត្ថា*
*វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*
*រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០០៩*

# ជំពូកទី ១. សេចក្តីផ្តើម

នៅឆ្នាំ២០០៧ វិស័យកសិកម្មរបស់កម្ពុជារួមចំណែក ២៧% នៃផលិតផលក្នុងស្រុកសរុប (ផសស) និងប្រើប្រាស់កម្លាំងពលកម្ម ៥៦% នៃកម្លាំងពលកម្មសរុប ហើយកម្លាំងទាំងនោះភាគច្រើនជាពលរដ្ឋក្រីក្រ (IMF 2009) ។ ទោះជាយ៉ាងណាក្តី ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ វិស័យកសិកម្មបានរីកចំរើនក្នុងល្បឿនយឺត ដោយមានកំណើនជាមធ្យម ៣,៣% ក្នុងមួយឆ្នាំ ចំណែកឯពាណិជ្ជកម្មក្នុងវិស័យនេះ មិនបានរួមចំណែកច្រើនដល់ពាណិជ្ជកម្មសរុបរបស់កម្ពុជាឡើយ ទោះបីជាកម្ពុជាមានឧត្តមភាពប្រៀបធៀបលើវិស័យនេះក្តី ។ នៅឆ្នាំដដែលនេះ ការនាំចេញផលិតផលកសិកម្មសរុបមាន ចំនួន ១០៦,៣លានដុល្លារអាមេរិក ឬ ២,៦% នៃការនាំចេញសរុប ខណៈដែលការនាំចូលផ្នែកកសិកម្ម មានចំនួន ២៨២,១លានដុល្លារអាមេរិក ឬ ៥,២% នៃការនាំចូលសរុប[១] ។ ចំពោះពាណិជ្ជកម្មនៅក្នុងមហាអនុតំបន់មេគង្គ (GMS) ការនាំចេញផ្នែកកសិកម្មរបស់កម្ពុជាទៅកាន់បណ្តាប្រទេស GMS មានប្រមាណ ២២% នៃការនាំចេញសរុប ខណៈដែលការនាំចូលផ្នែកកសិកម្មមានទំហំ ៦២% នៃការនាំចូលសរុបផ្នែកកសិកម្ម ។ ប្រទេសថៃ គឺជាដៃគូពាណិជ្ជកម្មធំបំផុតរបស់កម្ពុជាសំរាប់ផលិតផលកសិកម្ម បន្ទាប់មកគឺប្រទេសចិន (ជាប្រភពធំបំផុតលំដាប់ទីពីរសំរាប់ការនាំចូល និងជាគោលដៅនាំចេញធំបំផុតលំដាប់ទីបី) និងប្រទេសវៀតណាម[២] ។

ពាណិជ្ជកម្មកសិកម្មរបស់កម្ពុជាជាមួយបណ្តាប្រទេសនៅក្នុង GMS ស្ថិតនៅក្រោមកម្មវិធីពាណិជ្ជកម្មអនុគ្រោះជាច្រើន ពោលគឺ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-តារាងអនុគ្រោះពន្ធគយមានប្រសិទ្ធភាពរួម (ASEAN-CEPT) សំរាប់ពាណិជ្ជកម្មជាមួយសមាជិកអាស៊ាន និងកម្មវិធីប្រមូលផលដើមដៃ (EHP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មលើទំនិញក្រោមកិច្ចព្រមពៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) សំរាប់ពាណិជ្ជកម្មជាមួយប្រទេសចិន ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងនោះ តម្រូវឱ្យប្រទេសកម្ពុជាកាត់បន្ថយ និងលុបចោលនូវពន្ធគយ និងរបាំងមិនមែនពន្ធគយ ចំពោះការផ្តោះប្តូរកសិកម្ម ដើម្បីបានចូលក្នុងទីផ្សារធំទូលាយ សំរាប់ការនាំចេញផលិតផលកសិកម្ម ទៅក្នុងទីផ្សាររបស់ពួកដៃគូកម្ពុជា (គោលការណ៍ "បដិការ") ។ ជាគោលការណ៍ ការធ្វើបែបនេះវាជួយជំរុញចរាចរទំនិញកសិកម្មនៅក្នុងតំបន់ ហើយចលនានេះនឹងនាំទៅដល់ឯកទេសភាវូបនីយកម្ម ទៅតាមលក្ខណៈអំណោយផលនៃធនធានរបស់ប្រទេសនីមួយៗ ។ ទោះបីជាកម្ពុជាមានឧត្តមភាពប្រៀបធៀបជាសក្តានុពល លើវិស័យផលិតកម្មកសិកម្មដោយសារកម្ពុជាសម្បូណ៌ដីដែលអាចដាំដុះបានក្តី ក៏កម្ពុជានៅខ្វះខាតជំនាញ (Toshiyashu, Chan and Long, 1998[3]) ។ សូម្បីតែនៅពេលមានភាពប្រកួតប្រជែងអាចប្រៀបធៀបគ្នាបាន សំរាប់ទំនិញកសិកម្មមួយចំនួន ដូចជា ពោត សណ្តែកសៀង និងដំឡូងឈើ ជាដើម ក៏ការនាំចេញកសិផលរបស់កម្ពុជានៅមានចំនួនតិចតួច ។ ប្រការនេះអាចមានន័យថា កម្ពុជានៅមិនទាន់ទាញផលចំណេញបានពេញលេញពីកិច្ចសន្យាពាណិជ្ជកម្មនៅឡើយទេ ។ កត្តាចំបងដែលនាំទៅដល់លទ្ធផលបែបនេះគឺ សមត្ថភាពផ្គត់ផ្គង់មានតិច ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីកន្លែងផលិតទៅកាន់មាត់ច្រកនាំចេញនៅមិនទាន់រឹងមាំ កង្វះព័ត៌មានទីផ្សារ និងកង្វះសេវាគាំទ្រពាណិជ្ជកម្ម ព្រមទាំងចំណាយសម្រួលពាណិជ្ជកម្មមានកំរិតខ្ពស់ ។

---

១ ស្ថិតិពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ២០០៩ ។

២ UN ComTrade 2008.

៣ អ្នកនិពន្ធទាំងនេះ សិក្សាអំពីកត្តាកំណត់ឧត្តមភាពប្រៀបធៀបរបស់បណ្តាប្រទេសអាស៊ាន ផ្អែកលើភស្តុតាងជាក់ស្តែងពីការសិក្សាឆ្លងដែនធ្វើឡើងដោយ Wood (1994) ។

ដោយបានទទួលស្គាល់យ៉ាងច្បាស់ពីសារៈសំខាន់នៃការអភិវឌ្ឍវិស័យពាណិជ្ជកម្មកសិកម្ម ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងអនុវត្តវិធីសាស្ត្រទ្វេទិស ក្នុងការជំរុញនាំចេញផលិតផលកសិកម្ម និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ។ ក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម និងដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងអ្នកផ្តល់ជំនួយដទៃទៀត រដ្ឋាភិបាលកម្ពុជាបានប្រកាសអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មមួយមានឈ្មោះថា ការសិក្សាពីស្ថានភាពសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (DTIS) ឆ្នាំ២០០៧ នៅពាក់កណ្តាលឆ្នាំ២០០៦ ដើម្បីមានទស្សនៈកាន់តែច្បាស់លាស់ និងជាយុទ្ធសាស្ត្រ អំពីការអភិវឌ្ឍវិស័យពាណិជ្ជកម្មកម្ពុជា ។ គោលដៅជាក់លាក់នៃ DTIS ឆ្នាំ២០០៧ មានដូចតទៅ: កំណត់អត្តសញ្ញាណផលិតផល ឬសេវាកម្ម អាទិភាពសំរាប់ធ្វើជាមូលដ្ឋាន ដើម្បីពង្រីង និងធ្វើពិពិធកម្មវិស័យនាំចេញរបស់កម្ពុជា កំណត់ចំណុចរាំងស្ទះដែលត្រូវលុបបំបាត់ដើម្បីជំរុញការអភិវឌ្ឍវិស័យនាំចេញនានា និងធ្វើជាមូលដ្ឋានសំរាប់កំណត់អាទិភាពនៃការអភិវឌ្ឍវិស័យពាណិជ្ជកម្ម ។ ក្នុងចំណោមវិស័យទាំង ១៩ ដែល DTIS ឆ្នាំ២០០៧ បានកំណត់ថាមានសក្តានុពលសំរាប់ការនាំចេញ គឺមានទំនិញកសិកម្ម ៩ មុខ (ស្វាយចន្ទី ជ័រឡូងឈើ ពោត ជលផល បសុសត្វ អង្ករ កៅស៊ូ សណ្តែកសៀង ផ្លែឈើ និងបន្លែ) ។

DTIS ឆ្នាំ២០០៧ បានធ្វើការវិភាគស៊ីជម្រៅមួយអំពីលទ្ធផលនៃការនាំចេញ តម្រូវការពីទីផ្សារពិភពលោក ស្ថានភាពផ្គត់ផ្គង់នៅក្នុងស្រុក និងផលប៉ះពាល់នៃការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាបណ្តាផែនការសកម្មភាពពាក់ព័ន្ធគ្នាខាងផ្នែកច្បាប់ និងខាងផ្នែកស្ថាប័ន សំរាប់វិស័យមានសក្តានុពលនាំចេញទាំង ១៩ ដែលសំដៅពង្រឹងបរិយាកាសអាជីវកម្ម និងវិនិយោគ ដើម្បីអភិវឌ្ឍការនាំចេញ ។ ប៉ុន្តែ DTIS ឆ្នាំ២០០៧ មិនបានលើកមកពិភាក្សានូវទិដ្ឋភាពសំខាន់ៗដទៃទៀតទេ ដូចជា ចំណាយផលិតកម្មប្រៀបធៀបនៃទំនិញកសិកម្មជ្រើសរើសមួយចំនួន ខ្សែរយៈទីផ្សារ បញ្ហាប្រឈម និងឱកាសល្អ សំរាប់ផលិតកម្មកសិកម្មនិងការរកទីផ្សារ និងលំហូរទីផ្សារក្នុងតំបន់ ។ ដោយសារកន្លងមក គ្មានការសិក្សាណាមួយលើបញ្ហាទាំងនេះ ដើម្បីលើកកំពស់ពាណិជ្ជកម្មកសិកម្មនៅក្នុង GMS ការសិក្សានេះ ក៏ត្រូវបានរចនារៀបចំដើម្បីបំពេញកង្វះខាតចំណេះដឹងលើផ្នែកនេះ ។ ការសិក្សានេះមានគោលដៅពិនិត្យមើលថា តើពាណិជ្ជកម្មកសិកម្មនៅក្នុងតំបន់អាចជំរុញឡើងយ៉ាងដូចម្តេច ដើម្បីទទួលបានផលចំណេញច្រើនបំផុត និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានា ។ ការសិក្សានេះជ្រើសយកជ័រឡូងឈើ និងកៅស៊ូ មកធ្វើការវិភាគស៊ីជម្រៅ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចតទៅ: (១) ទំនិញទាំងនេះត្រូវការការស្រាវជ្រាវ និងអន្តរាគមន៍ផ្នែកគោលនយោបាយ ហើយពីមុនមកមិនដែលមានការសិក្សាអ្វីគួរកត់សំគាល់ទេលើផ្នែកនេះ និង (២) សារៈសំខាន់នៃទំនិញនានាផ្អែកលើសក្តានុពលនាពេលបច្ចុប្បន្ន និងទៅអនាគត ក្នុងការបង្កើតការងារ និងការកាត់បន្ថយភាពក្រីក្រ ។

របាយការណ៍នេះចែកចេញជាប្រាំពីរជំពូក ។ ជំពូកទី ១ ជាសេចក្តីផ្តើមបង្ហាញពីផលិតម្ម និងពាណិជ្ជកម្មកសិកម្ម ។ ជំពូកទី២ពិភាក្សាពីវិធីសាស្ត្រស្រាវជ្រាវដែលការសិក្សានេះប្រើប្រាស់ ។ជំពូកទី៣ពិនិត្យលើផ្នែកនានានៃផលិតកម្មជ័រឡូងឈើ និងកៅស៊ូ ដោយផ្តោតលើវិធីផលិត ចំណាយផលិតកម្ម បញ្ហាប្រឈម និងឱកាសល្អ សំរាប់ផលិតកម្ម ។ ជំពូកទី ៤ ពិនិត្យលើពាណិជ្ជកម្មជ័រឡូងឈើ ជាពិសេសពិនិត្យពីផ្នែកនានានៃលំហូរពាណិជ្ជកម្ម ចំណាយនិងចំណេញពាណិជ្ជកម្ម និងបញ្ហាប្រឈម និងឱកាសល្អសំរាប់ការរកទីផ្សារ ។ ជំពូកទី ៥ អនុសាសន៍ផ្នែកគោលនយោបាយ និងសេចក្តីសន្និដ្ឋាន ។

# ជំពូកទី ២. វិធីសាស្ត្រ

ដើម្បីដោះស្រាយលើសំណួរគន្លឹះទាំងឡាយ ការសិក្សានេះបានប្រើវិធីសាស្ត្រពីររួមគ្នាគឺ ការស្រាវជ្រាវឯកសារនៅនឹងកន្លែង និងការចុះអង្កេតជាក់ស្តែង ។ សកម្មភាពចំបងក្នុងការស្រាវជ្រាវឯកសារនៅនឹងកន្លែង រួមមានការពិនិត្យមើលឡើងវិញនូវឯកសារគោលនយោបាយ ឯកសារសំណេរនានា និងការពិនិត្យត្រួសៗនូវទិន្នន័យផ្នែកស្ថិតិ ។ អង្កេតជាក់ស្តែងនៅមូលដ្ឋាន រួមមាន អង្កេតកសិករ អង្កេតពាណិជ្ជករ និងសម្ភាសន៍ជាមួយជនបង្គោល ដូចជា ប្រធានភូមិ និងអភិបាលស្រុក មន្ត្រីកសិកម្មស្រុក និងតំណាងក្រុមហ៊ុនកែច្នៃ ។ អង្កេតជាក់ស្តែងបានប្រព្រឹត្តទៅនៅខែឧសភា ឆ្នាំ២០០៧ នៅពីរខេត្ត គឺ បាត់ដំបង និងកំពង់ចាម ដែលជាកន្លែងផលិតកសិផលជាកម្មវត្ថុនៃការសិក្សា និងជាកន្លែងមានពាណិជ្ជកម្មឆ្លងដែនច្រើនជាមួយប្រទេសជិតខាង ។ កំពង់ចាម ជាខេត្តមួយស្ថិតនៅភាគខាងកើត រីឯបាត់ដំបងជាខេត្តស្ថិតនៅភាគខាងលិចនៃប្រទេសកម្ពុជា ។ ស្រុកពីរ នៅខេត្តកំពង់ចាមគឺ មេមត់ និងពញាក្រែក ត្រូវបានជ្រើសរើសមកធ្វើការសិក្សាលើដំណាំកៅស៊ូ និងដំឡូងឈើ ចំណែកឯនៅបាត់ដំបងវិញ ស្រុកកំរៀងត្រូវបានជ្រើសរើសសំរាប់ធ្វើអង្កេតអំពីដំឡូងឈើ (សូមមើលផែនទី) ។

### អង្កេតកសិករ

អង្កេតនេះបានធ្វើឡើងដើម្បីប្រមូលព័ត៌មានពីកសិករលើដំណើរការផលិត ចំណាយផលិតកម្ម បញ្ហាប្រឈមចំពោះការផលិត ការកំណត់ថ្លៃ និងប្រាក់ចំណេញ ។ សំរាប់ដំឡូងឈើ កសិករ ៣៧នាក់ នៅខេត្តបាត់ដំបង និង ៣២នាក់ នៅខេត្តកំពង់ចាម ត្រូវបានជ្រើសរើសដោយចៃដន្យសំរាប់អង្កេត ។ សំរាប់កៅស៊ូវិញ អង្កេតបានធ្វើឡើងទៅតែនៅក្នុងខេត្តកំពង់ចាមប៉ុណ្ណោះ ហើយកសិករ ៣៩នាក់ ត្រូវបានជ្រើសរើស ។

ក្រាហ្វិក ២.១: ផែនទីបង្ហាញទីតាំងភូមិសាស្ត្រនៃការសិក្សា



### អង្កេតពាណិជ្ជករ

អង្កេតពាណិជ្ជករបានធ្វើឡើងដើម្បីប្រមូលព័ត៌មានស្ដីពី ខ្សែរយៈទីផ្សារ លំហូរពាណិជ្ជកម្ម ព្រមទាំងចំណាយ និងចំណេញ ពាក់ព័ន្ធនឹងពាណិជ្ជកម្មផលិតផលដែលជាកម្មវត្ថុនៃការសិក្សា ។ សំណួរដែលបានរៀបចំជាមុន ត្រូវបានយកមកសួរដើម្បីស្វែងយល់ពីបញ្ហារួមខ្លះ ប៉ុន្តែមិនអាចក្ដាប់ដំណើររឿងបានទាំងស្រុងទេ ។ ដើម្បីបំពេញចំណុចខ្វះខាតនេះ ការសិក្សាក៏បានធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយពាណិជ្ជករផងដែរ ដោយព្យាយាមស្វែងយល់ពីសកម្មភាពពាណិជ្ជកម្មរបស់ពាណិជ្ជករម្នាក់ៗ និងពីទិដ្ឋភាពរួមនៃពាណិជ្ជកម្មផលិតផលនៅក្នុងតំបន់របស់ពួកគេ ។

### សម្ភាសន៍ជនបង្គោល

ការសិក្សាបានធ្វើសម្ភាសន៍ស៊ីជម្រៅជាច្រើនជាមួយប្រធានភូមិ អភិបាលស្រុក និងមន្ត្រីកសិកម្ម ដើម្បីស្វែងយល់ពីស្ថានភាព និងលក្ខខណ្ឌរួមនៃផលិតកម្ម និងពាណិជ្ជកម្មកសិកម្មនៅក្នុងភូមិ និងស្រុកនីមួយៗ ។ ក្រុមស្រាវជ្រាវក៏បានសម្ភាសជាមួយតំណាងរោងចក្រកែច្នៃដំឡូងឈើនៅកំពង់ចាម ដើម្បីស្វែងយល់ពីដំណើការរកប្រភព និងដំណើរការលក់ផងដែរ ។

# ជំពូកទី ៣. ផលិតកម្ម

## ៣.១. ដំឡូងឈើ

### ៣.១.១. និន្នាការទូទៅនៃផលិតកម្មដំឡូងឈើ

ក្រាហ្វិក ៣.១ បង្ហាញពីប្រវត្តិនៃការអភិវឌ្ឍផលិតកម្មដំឡូងឈើនៅកម្ពុជា ដោយផ្តល់ព័ត៌មានពីផ្ទៃដីដាំដុះ បរិមាណផលិតកម្មសរុប និងផលិតភាព ។ ក្រាហ្វិកនេះបង្ហាញថា ផលិតកម្មដំឡូងឈើបានរីកចម្រើនយ៉ាងឆាប់រហ័សនៅចន្លោះឆ្នាំ២០០៥ និង ២០០៦ ។ បរិមាណផលិតកម្មសរុបឡើងដល់ ២,១៩លានតោន នៅឆ្នាំ២០០៦ ដោយកើនពី ០,៥៤លានតោន នៅឆ្នាំ២០០៥ និង ០,១៨លានតោន នៅឆ្នាំ២០០០ ។ កំណើនដ៏ឆាប់រហ័សនៃបរិមាណផលិតកម្មសរុប វាជាប់ទាក់ទងមួយផ្នែកធំ ទៅនឹងកំណើនយ៉ាងឆាប់រហ័សនៃផ្ទៃដីដាំដុះ និងកំណើនផលិតភាព ។ ផ្ទៃដីដាំដុះនៅឆ្នាំ២០០៦ កើនដល់ ៩៦.៣២៤ហិកតា គឺធំជាងផ្ទៃដីដាំដុះនៅឆ្នាំ២០០៥ ចំនួន ៣ដង និងធំជាងផ្ទៃដីដាំដុះនៅឆ្នាំ២០០០ ចំនួន ៦ដង ។ ទិន្នផលមធ្យមនៅឆ្នាំ២០០៦ គឺ ២២,៦៥តោនក្នុងមួយហិកតា ធៀបនឹង ១៧,៨៧តោនក្នុងមួយហិកតា នៅឆ្នាំ២០០៥ និង ១០,៤៧តោនក្នុងមួយហិកតា នៅឆ្នាំ២០០១ ។

ចំពោះរបាយតាមខេត្តវិញ ខេត្តកំពង់ចាមជាកន្លែងផលិតធំជាងគេបំផុត (យ៉ាងហោចណាស់នៅឆ្នាំ២០០៥) ដោយមានផ្ទៃដីដាំដុះ ១១.៧១៩ហិកតា និងបរិមាណផលិតកម្ម ២៤៤.៦០៥តោន ។ នៅឆ្នាំដដែលនេះ ទិន្នផលមធ្យមនៅកំពង់ចាម មានកម្រិតខ្ពស់ជាងគេលំដាប់ទីពីរគឺ ២០,៩តោនក្នុងមួយហិកតា ។ កំពង់ស្ពឺ ជាខេត្តផលិតដំឡូងឈើធំជាងគេលំដាប់ទីពីរ បន្ទាប់មកគឺ ខេត្តសៀមរាប កំពង់ធំ បាត់ដំបង និងព្រះវិហារ (ព័ត៌មានលំអិតបន្ថែមមានចុះក្នុងតារាង ៣.១) ។ ផ្ទៃដីដាំដុះនៅក្នុង ៥ខេត្ត ដែលមានការដាំដុះជាងគេ មានដល់ ៧៨% នៃផ្ទៃដីដាំដុះសរុប ហើយបរិមាណផលិតកម្មនៃខេត្តទាំងនេះមានដល់ ៩២% នៃផលិតកម្មដំឡូងឈើសរុបនៅកម្ពុជានៅឆ្នាំ២០០៥ ។

**ក្រាហ្វិក ៣.១: ផលិតកម្មដំឡូងឈើនៅកម្ពុជា**




ប្រភព: *FAOSTAT*

**តារាង ៣.១: ផលិតកម្មដំឡូងឈើនៅតាមខេត្តមួយចំនួននៅឆ្នាំ ២០០១ និង ២០០៥**

| | 2005 | | | 2001 | | |
|---|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ហិកតា) | ទិន្នផល (តោន/ហិកតា) | ផលិតផល (តោន) | ផ្ទៃដីដាំដុះ (ហិកតា) | ទិន្នផល (តោន/ហិកតា) | ផលិតផល (តោន) |
| កំពង់ចាម | 11,719 | 20.9 | 244,605 | 4,639 | 11.97 | 55,520 |
| កំពង់ស្ពឺ | 3,269 | 14.7 | 47,698 | 1,200 | 6.8 | 8,160 |
| សៀមរាប | 1,182 | 11.6 | 13,698 | 1,222 | 8.59 | 8,118 |
| កំពង់ធំ | 895 | 7 | 6,009 | 1,927 | 6.52 | 10,295 |
| បាត់ដំបង | 770 | 27 | 20,813 | 1,148 | 12 | 13,775 |
| ព្រះវិហារ | 681 | 10 | 6,810 | 93 | 10 | 900 |
| តាកែវ | 582 | 6 | 3,499 | 695 | 8.98 | 6,179 |
| ក្រៅពីនេះ | 3,651 | - | 18,918 | 5,355 | - | 44,816 |

*ប្រភព: ស្ថិតិកសិកម្មឆ្នាំ ២០០០-២០០១ និង ២០០៤-២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ចំពោះផលិតភាពវិញ នៅឆ្នាំ២០០៥ វាប្រែប្រួលខុសគ្នាច្រើនទៅតាមខេត្ត ដោយមានកំរិតខ្ពស់បំផុតដល់ ២៧តោនក្នុងមួយហិកតា និងទាបបំផុតត្រឹមតែ ២,៥តោនក្នុងមួយហិកតា ។ ខេត្តបាត់ដំបងមានផលិតភាពខ្ពស់ជាងគេ បន្ទាប់មកគឺ កំពង់ចាម (២០,៩តោនក្នុងមួយហិកតា) កោះកុង (១៩តោនក្នុងមួយហិកតា) និងកំពង់ស្ពឺ (១៤,៧តោនក្នុងមួយហិកតា) ។ ខេត្តមានផលិតភាពទាបជាងគេគឺមាន ខេត្តពោធិសាត់ និងខេត្តមួយចំនួនទៀត ដូចជា កំពង់ឆ្នាំង (៣,២តោនក្នុងមួយហិកតា) កំពត (៣,៧តោនក្នុងមួយហិកតា) ស្ទឹងត្រែង (៤,០តោនក្នុងមួយហិកតា) និងស្វាយរៀង (៤,៥តោនក្នុងមួយហិកតា) ។

### ៣.១.២. របៀបរបបដាំដុះ

ដំឡូងឈើ ជាដំណាំមួយប្រភេទដែលអាចបន្សាំតាមធាតុអាកាសច្រើនបែបច្រើនយ៉ាង ហើយគេអាចដាំវានៅលើដីមិនសូវមានជីជាតិ អាចដាំវាជាដំណាំតែមួយមុខ ឬដាំឆ្លាស់ជាមួយដំណាំដទៃទៀត ដូចជា ពោត ដំណាំបន្លែ កៅស៊ូ និងរុក្ខជាតិដទៃទៀត ។ តាមធម្មតាគេដាំដំឡូងឈើនៅក្នុងអំឡុងខែកុម្ភៈ-មេសា ហើយប្រមូលផល ៨-១២ខែក្រោយ យោងតាមថ្លៃទីផ្សារ និងលទ្ធភាពរកបានកម្លាំងពលកម្មសំរាប់ការប្រមូលផល ។ របៀបដាំដុះនៅបណ្តាខេត្តភាគខាងលិច និងខាងកើតនៃប្រទេសកម្ពុជា មានលក្ខណៈដូចគ្នាលើចំណុចជាច្រើន ហើយមានការខុសគ្នាគួរកត់សំគាល់តែ ២-៣ចំណុចប៉ុណ្ណោះ ដោយសារដី និងធាតុអាកាសខុសគ្នា ។

នៅស្រុកកំរៀង ខេត្តបាត់ដំបង គេដាំដំឡូងឈើតែមួយមុខ ហើយតាមធម្មតា គេដាំនៅពាក់កណ្តាលខែមីនា ដោយអាចដាំយ៉ាងឆាប់បំផុតនៅខែកុម្ភៈ និងយឺតបំផុតនៅខែមេសា ។ ការភ្ជួរដីលើកទីមួយ ចាប់ធ្វើនៅខែមីនា មុនពេលមានភ្លៀងធ្លាក់ ហើយការភ្ជួរលើកទីពីរ និងលើករង ធ្វើឡើងនៅពាក់កណ្តាលខែមីនា ។ កសិករភាគច្រើន ជួលម្ចាស់ត្រាក់ទ័រនៅទីនោះឱ្យភ្ជួរដី និងជួលពលករជាច្រើននាក់ឱ្យលើករងសំរាប់ដាំ ។ កសិករភាគច្រើនភ្ជួរដីពីរដង និងមានប្រមាណ ៥% ភ្ជួរដីតែម្តងប៉ុណ្ណោះ ដោយសារខ្វះប្រាក់ ។ ភាពខុសគ្នាជាចំបងរវាងជម្រើសទាំងពីរគឺ ទិន្នផលខុសគ្នា ដោយរបៀបរបបដែលមានការរៀបចំដីម៉ត់ចត់ វាផ្តល់ទិន្នផលខ្ពស់ជាង ។

តាមធម្មតា គេដាំដើមដំឡូងឈើនៅខែមេសា ដោយកសិករភាគច្រើនប្រើដើមដំឡូងរបស់ខ្លួនផ្ទាល់ ដែលគេបានកាត់ទុកនៅពេលប្រមូលផលលើកមុន ។ នៅស្រុកកំរៀង ការប្រើថ្នាំសម្លាប់ស្មៅ គឺជាការចាំបាច់ ហើយយ៉ាងហោចណាស់

គេដាក់ថ្នាំសម្លាប់ស្មៅពីរលើក នៅពេលដែលស្មៅដុះវែងហើយក្រាស់ ។ ការដាក់ថ្នាំសម្លាប់ស្មៅលើកទីមួយ ធ្វើឡើងនៅពាក់កណ្តាលខែឧសភា ហើយការដាក់ថ្នាំសម្លាប់ស្មៅលើកទីពីរ នៅពេលមួយខែកន្លះក្រោយមកទៀត ។ ក្នុងចំណោមកសិករ ការដាក់ថ្នាំសម្លាប់ស្មៅលើកទីបី អនុវត្តមិនដូចគ្នាទេ គឺអាស្រ័យលើស្ថានភាពស្មៅ និងលើលទ្ធភាពហិរញ្ញវត្ថុរបស់ពួកគេ ។ ជាចុងក្រោយ ការកាត់មែកខ្លះនៃដើមដំឡូងឈើ តាមធម្មតាគេធ្វើឡើងប្រហែលមួយខែមុនពេលប្រមូលផល ដើម្បីធ្វើឱ្យមានពន្លឺថ្ងៃគ្រប់គ្រាន់សំរាប់ឱ្យមើមដំឡូងរីកធំ ។

ដំណើរការទាំងមូលនៃការដាំដុះដំឡូងឈើនៅស្រុកមេមត់ ខេត្តកំពង់ចាម មានលក្ខណៈដូចគ្នានឹងតំបន់ភាគខាងលិចដែរ ។ ភាគច្រើនគេដាំដំឡូងឈើជាមួយដំណាំដទៃទៀត ពិសេសជាមួយដើមកៅស៊ូក្នុងអំឡុងខែមេសា-ឧសភា ហើយប្រមូលផលនៅខែធ្នូ-មករា ។ ក្នុងករណីភាគច្រើន កសិករប្រើបាស់កម្លាំងពលកម្មច្រើនជាខ្លាំង ជាជាងការប្រើត្រាក់ទ័រក្នុងការរៀបចំដី ពីព្រោះគេដាំដំឡូងឈើនៅចន្លោះដំណាំផ្សេងៗទៀត ។ ប៉ុន្តែខុសប្លែកពីកសិករនៅតំបន់ភាគខាងលិចដែលប្រើថ្នាំយ៉ាងច្រើន ដើម្បីសម្លាប់ស្មៅដែលដុះខ្ពស់ និងដុះក្រាស់ នៅតំបន់នោះ កសិករនៅមេមត់មានប្រើថ្នាំសម្លាប់ស្មៅតិចតួចបំផុត ។ ការធ្វើបែបនេះធ្វើឱ្យកសិករនៅមេមត់ សំចៃប្រាក់បានយ៉ាងច្រើន និងធ្វើឱ្យថយចុះចំណាយផលិតកម្ម ។

**ក្រាហ្វិក ៣.២: ដំណើរការ និងពេលវេលាដាំដុះដំឡូងឈើ**



### ៣.១.៣. ចំណាយផលិតកម្ម

ចំណាយផលិតកម្មដំឡូងឈើ រួមមាន មុខចំណាយសំខាន់ៗដូចតទៅ: ការជួលដី ការរៀបចំដី ពលកម្ម និងឥណទាន ។ ដោយសារចំណាយផលិតកម្មប្រែប្រួលខុសគ្នាខ្លាំងណាស់ រវាងតំបន់សិក្សាទាំងពីរ ដូច្នេះការវិភាគនៅខាងក្រោមបានបែងចែកការគណនាចំណាយផលិតកម្មជាពីរផ្នែកគឺ ចំណាយផលិតកម្មនៅភាគខាងលិច និងចំណាយផលិតកម្មនៅភាគខាងកើត ។

#### ចំណាយផលិតកម្មនៅភាគខាងលិច

ចំណាយទាំងអស់ត្រូវបានប្រមូលផ្តុំជាពីរក្រុម: ចំណាយផ្សារភ្ជាប់ជាមួយកត្តាផលិតកម្មរបស់គ្រួសារ និងចំណាយលើការទិញកត្តាផលិតកម្មនានា ។ កសិករស្ទើរតែទាំងអស់ (៩៩ភាគរយ) បានដាំដំឡូងឈើលើដីរបស់ខ្លួន ។ ទោះជាពួកគាត់មិនត្រូវការចំណាយលើថ្លៃជួលដីក្តី ក៏ការប៉ាន់ស្មានចំណាយផ្អែកលើមូលដ្ឋាននៃការជួលដីនៅឆ្នាំ២០០៧ និងផ្អែកលើថ្លៃជួលដីនៅទីផ្សារគឺ ១១៩,៩៥ដុល្លារអាមេរិកក្នុងមួយហិកតា ។

ចំណាយរៀបចំដី រួមមាន ចំណាយលើការភ្ជួរ និងការលើករង ដែលជាទូទៅកសិករជួលម្ចាស់ត្រាក់ទ័រឱ្យធ្វើ ។ ជាមធ្យមនៅឆ្នាំ២០០៧ ចំណាយភ្ជួរដីលើកទីមួយគឺ ៤៨,៥៣ដុល្លារអាមេរិកក្នុងមួយហិកតា និងលើកទីពីរ ៤១,៧៥ដុល្លារអាមេរិក ។ ថ្នាំសម្លាប់ស្មៅ និងដើមដំឡូង គឺជាកត្តាផលិតកម្មចំបងនៃផលិតកម្មដំឡូងឈើ ហើយចំណាយសរុបលើថ្នាំសម្លាប់ស្មៅ និងដើមដំឡូងនៅឆ្នាំ២០០៧ គឺ ៨៥,៥២ដុល្លារក្នុងមួយហិកតា ក្នុងនេះចំណាយលើថ្នាំសម្លាប់ស្មៅ គឺ ៤៦,១៦ដុល្លារអាមេរិក ហើយចំណាយលើដើមដំឡូង គឺ ៣៩,៣៦ដុល្លារក្នុងមួយហិកតា ។

**តារាង ៣.២: ចំណាយផលិតកម្មដំឡូងឈើនៅស្រុកកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧**

| មុខចំណាយ | ឯកតា | កត្តាផលិតកម្មគ្រួសារគិតជាប្រាក់ | | | ចំណាយលើការទិញ | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | បរិមាណ | ថ្លៃ/ឯកតា | ទឹកប្រាក់ | បរិមាណ | ថ្លៃ/ឯកតា | ទឹកប្រាក់ | ទឹកប្រាក់ |
| **ក. ចំណាយលើដី** | ដុល្លារអាមេរិក | - | - | **119.95** | - | - | **2.03** | **121.98** |
| **ខ. ចំណាយលើការរៀបចំដី** | ដុល្លារអាមេរិក | - | - | 0 | - | - | **90.28** | **90.28** |
| - ភ្ជួរលើកទី ១ | ដុល្លារអាមេរិក | - | - | 0 | - | - | 48.53 | 48.53 |
| - ភ្ជួរលើកទី ២ | ដុល្លារអាមេរិក | - | - | 0 | - | - | 41.75 | 41.75 |
| **គ. ចំណាយលើកត្តាផលិតកម្ម** | ដុល្លារអាមេរិក | - | - | **26.24** | - | - | **59.28** | **85.52** |
| - ដើមដំឡូង | - | - | - | 26.24 | - | - | 13.12 | 39.36 |
| - ថ្នាំសម្លាប់ស្មៅ | កំប៉ុង | 0 | 0 | 0 | 37.8 | 1.22 | 46.16 | 46.16 |
| **ឃ. ចំណាយពលកម្ម** | នាក់-ថ្ងៃ | 8 | 2.77 | **20.89** | 25 | 2.77 | **68.4** | **89.29** |
| - ការរៀបចំដី | នាក់-ថ្ងៃ | 1 | 2.77 | 3.19 | 0 | 2.77 | 0.27 | 3.46 |
| - ការដាំ | នាក់-ថ្ងៃ | 2 | 2.54 | 6.09 | 10 | 2.54 | 25.98 | 32.07 |
| - ការធ្វើស្មៅ | នាក់-ថ្ងៃ | 4 | 2.89 | 10.13 | 8 | 2.89 | 22.91 | 33.04 |
| - ការកាត់មែក | នាក់-ថ្ងៃ | 1 | 2.77 | 1.48 | 7 | 2.77 | 19.24 | 20.72 |
| **ង. ចំណាយលើប្រាក់កម្ចី** | % ក្នុងមួយខែ | - | - | 0 | - | 3.42% | **60.8** | **60.8** |
| **ច. ចំណាយផ្សេងទៀត** | ដុល្លារអាមេរិក | - | - | 0 | - | - | **16.91** | **16.91** |
| **ចំណាយសរុប** | ដុល្លារអាមេរិក | **-** | **-** | **167.1** | **-** | **-** | **297.7** | **464.8** |

*ប្រភព: ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យរបស់ វបសអ បានពីអង្កេតលើកសិករដាំដំឡូងឈើនៅឆ្នាំ២០០៨*

ចំណាយពលកម្ម ក៏ជាចំណាយផលិតកម្មមួយខ្ពស់ដែរក្នុងការដាំដុះដំឡូងឈើ ដែលត្រូវប្រើកម្លាំងពលកម្មច្រើន ។ បន្ថែមលើពលករដែលជាសមាជិកគ្រួសារ កសិករត្រូវជួលពលករដទៃទៀតសំរាប់ដំណើរការផលិតកម្មទាំងមូល ។ កង្វះពលកម្មជាបញ្ហាស្រួចស្រាវ និងជាបន្ទុកចំណាយមួយយ៉ាងធំ ពីព្រោះគេត្រូវបង់ថ្លៃពលកម្មជាមធ្យម ២,៧៧ដុល្លារក្នុងពលករម្នាក់ក្នុងមួយថ្ងៃ ឬ ៦០,៨ដុល្លារអាមេរិកក្នុងមួយហិកតា នៅឆ្នាំ២០០៧ ។

ចំណាយសរុបនៃផលិតកម្មដំឡូងឈើនៅកំរៀង នៅឆ្នាំ២០០៧ គឺ ៤៦៤,៨ដុល្លារអាមេរិកក្នុងមួយហិកតា ក្នុងនោះ ចំណាយលើការជួលដី មាន ២៦% (ថ្លៃជួលដីត្រូវគិតចូល) ចំណាយលើការរៀបចំដី ១៩% ចំណាយលើកត្តាផលិតកម្ម ១៨% ចំណាយលើពលកម្ម ១៩% និង ចំណាយលើប្រាក់កម្ចី ១៣% ។ បន្ទុកចំណាយជាកត្តាផលិតកម្មរបស់គ្រួសារ គិតតាមថ្លៃទីផ្សារ មានចំនួនស្មើនឹង ៣៦% នៃចំណាយផលិតកម្មសរុប ហើយនៅឆ្នាំ២០០៧ ចំណាយភាគច្រើន គឺការទិញកត្តាផលិតកម្ម ។ តារាង ៣.២ បង្ហាញលំអិតនូវមុខចំណាយផលិតកម្មដំឡូងឈើនៅស្រុកកំរៀង ។

### ចំណាយផលិតកម្មដំឡូងឈើនៅភាគខាងកើត

តារាង ៣.៣ បង្ហាញជាសង្ខេបនូវចំណាយផលិតកម្មដំឡូងឈើនៅស្រុកមេមត់ ខេត្តកំពង់ចាម នៅឆ្នាំ២០០៧ ។ ចំណាយសរុបនៃផលិតកម្មដំឡូងឈើគឺ ៣២៩,១ដុល្លារអាមេរិកក្នុងមួយហិកតា ដែលជាចំណាយមួយទាបជាខ្លាំង ធៀបនឹងចំណាយផលិតកម្មដំឡូងឈើនៅស្រុកកំរៀង ។ ចំណាយលើជីថ្លីទំនងជាមានចំណែកធំជាងគេនៅក្នុងផលិតកម្ម គឺ ១៣១,៧៨ដុល្លារអាមេរិកក្នុងមួយហិកតា បន្ទាប់មក គឺចំណាយពលកម្ម ១១៣,៦២ដុល្លារអាមេរិកក្នុងមួយហិកតា នៅឆ្នាំ២០០៧ ។ ចំណាយលើកត្តាផលិតកម្មមានកំរិតខ្ពស់ជាងគេលំដាប់ទីបី គឺ ៤៦,៣២ដុល្លារអាមេរិកក្នុងមួយហិកតា បន្ទាប់មក គឺចំណាយរៀបចំដី ២២,៥៤ដុល្លារអាមេរិកក្នុងមួយហិកតា និងចំណាយលើប្រាក់កម្ចីស្មើនឹង ៧,៥៨ ដុល្លារអាមេរិកក្នុងមួយហិកតា នៅឆ្នាំ២០០៧ ។

កសិករនៅស្រុកមេមត់ ប្រើប្រាស់ថ្នាំសម្លាប់ស្មៅតិចជាងកសិករនៅស្រុកកំរៀងច្រើនណាស់ ហេតុនេះចំណាយលើមុខនេះ ក៏មានចំនួនតិចជាងច្រើនដែរ (៨,២៩ដុល្លារអាមេរិកក្នុងមួយហិកតា ធៀបនឹង ៤៦,១៦ដុល្លារអាមេរិកក្នុងមួយហិកតា) ។ ដើម្បីបានប្រាក់សំរាប់ធ្វើផលិតកម្មដំឡូងឈើ មានកសិករនៅភាគខាងកើតត្រឹម ៨% ប៉ុណ្ណោះ ដែលទៅខ្ចីពីអ្នកចងការប្រាក់ឯកជន រីឯអ្នកនៅភាគខាងលិចដែលទៅខ្ចីមានដល់ ៧៨% ។ ប្រការនេះធ្វើឱ្យចំណាយលើប្រាក់កម្ចីរបស់កសិករនៅភាគខាងកើតមានចំនួនតិចជាងយ៉ាងច្រើន ។

ចំពោះប្រភេទចំណាយវិញ ការគណនាចំណាយលើកត្តាផលិតកម្មគ្រួសារបង្ហាញថា ចំណាយនេះរួមចំណែក ៦២% ក្នុងចំណាយផលិតកម្មសរុប ហើយក្រៅពីនេះ គឺជាចំណាយលើការទិញកត្តាផលិតកម្មនៅឆ្នាំ២០០៧ ។ តួលេខនេះ វាផ្ទុយគ្នាពីលំនាំចំណាយនៅស្រុកកំរៀង និងជាការខុសគ្នាចំបងរវាងចំណាយផលិតកម្មនៅតំបន់ទាំងពីរ ។

**តារាង ៣.៣: ចំណាយផលិតកម្មដំឡូងឈើនៅស្រុកមេមត់ ខេត្តកំពង់ចាម ឆ្នាំ២០០៧**

| មុខចំណាយ | ឯកតា | កត្តាផលិតកម្មគ្រួសារគិតជាប្រាក់ | | | ចំណាយលើការទិញកត្តាផលិតកម្ម | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | បរិមាណ | ថ្លៃ/ឯកតា | ទឹកប្រាក់ | បរិមាណ | ថ្លៃ/ឯកតា | ទឹកប្រាក់ | ទឹកប្រាក់ |
| **ក.ចំណាយលើដី** | ដុល្លារអាមេរិក | - | - | **117.25** | - | - | **14.53** | **131.78** |
| **ខ.ចំណាយលើការរៀបចំដី** | ដុល្លារអាមេរិក | - | - | 0 | - | - | **22.54** | **22.54** |
| - ភ្ជួរលើទី ១ | ដុល្លារអាមេរិក | - | - | 0 | - | - | 14.38 | **14.38** |
| - ភ្ជួរលើកទី ២ | ដុល្លារអាមេរិក | - | - | 0 | - | - | 8.16 | **8.16** |
| **គ.ចំណាយលើកត្តាផលិតកម្ម** | ដុល្លារអាមេរិក | - | - | **22.82** | - | - | **23.5** | **46.32** |
| - ដើមដំឡូង | - | - | - | 22.82 | - | - | 15.21 | **38.03** |
| - ជី | គ.ក្រ | - | - | 0 | 82 | 0.0072 | 0.59 | 0.59 |
| - ថ្នាំសម្លាប់ស្មៅ | កំប៉ុង | - | - | 0 | 3 | 3.25 | 8.29 | **8.29** |
| **ឃ. ចំណាយពលកម្ម** | នាក់-ថ្ងៃ | 30 | - | **64.92** | 22.4 | - | **48.7** | **113.62** |
| - ការរៀបចំដី | នាក់-ថ្ងៃ | 8 | 2.13 | 16.12 | 3 | 2.13 | 5.94 | **22.06** |
| - ការដាំ | នាក់-ថ្ងៃ | 7 | 2.17 | 14.5 | 6 | 2.17 | 13.1 | **27.6** |
| - ការធ្វើស្មៅ | នាក់-ថ្ងៃ | 16 | 2.18 | 34.3 | 14 | 2.18 | 29.66 | **63.96** |
| **ង. ចំណាយលើប្រាក់កម្ចី** | % ក្នុងមួយខែ | - | - | 0 | - | 5.43 | **7.58** | **7.58** |
| **ច. ចំណាយផ្សេងទៀត** | ដុល្លារអាមេរិក | - | - | 0 | - | - | **7.22** | **7.22** |
| **ចំណាយសរុប** | ដុល្លារអាមេរិក | **-** | **-** | **205.0** | **-** | **-** | **124.1** | **329.1** |

*ប្រភព: ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យរបស់ វបសអ ដែលបានពីអង្កេតលើកសិករដាំដំឡូងឈើនៅឆ្នាំ២០០៨*

## ៣.១.៤ បញ្ហាប្រឈម និងឱកាសល្អ

### បញ្ហាប្រឈម

ក្នុងចំណោមដំណាំកសិផលសំរាប់លក់យកប្រាក់ ទោះបីជាដំឡូងឈើកាន់តែទាក់ទាញកសិករឱ្យជ្រើសយកវាក្តី ក៏ការដាំដុះ និងផលិតកម្មផលដំណាំនេះ ត្រូវជួបប្រទះបញ្ហាប្រឈមជាច្រើន ។ ការលំបាកបំផុតដែលកសិករតែងត្អូញត្អែរនោះ គឺការឡើងថ្លៃពលកម្ម និងថ្លៃកត្តាផលិតកម្មកសិកម្ម និងសេវាកម្ម ដែលបណ្តាលមកពីអតិផរណាខ្ពស់ ។ គេឃើញមានបញ្ហាកង្វះពលកម្ម ជាពិសេសនៅតំបន់ភាគខាងលិច ដែលពលរដ្ឋជាច្រើនបានធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ។ កំណើនបន្ទុកចំណាយនេះ ជំរុញឱ្យកសិករភាគច្រើន ជាពិសេសកសិករនៅភាគខាងលិចទៅខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ដោយបង់ការប្រាក់ខ្ពស់ ដើម្បីយកប្រាក់មកធ្វើផលិតកម្ម ហើយក៏ត្រូវបាត់បង់ប្រាក់ចំណេញជាច្រើនក្រោយពេលប្រមូលផល ។

បញ្ហាប្រឈមចំបងមួយទៀតចំពោះកសិករ គឺកង្វះការគាំទ្រក្នុងការចាប់ប្រើពូជដំឡូងមានទិន្នផលខ្ពស់ ។ គេមិនឃើញមានសេវាផ្សព្វផ្សាយកសិកម្មសំរាប់កសិករ ក្នុងការដោះស្រាយបញ្ហាបច្ចេកទេសដែលផុសឡើងនៅក្នុងដំណើរការផលិតកម្ម រឺក៏ព័ត៌មានទីផ្សារគ្រប់គ្រាន់ ស្តីពីថ្លៃដំឡូងឈើនៅទីផ្សារក្នុងតំបន់ និងទីផ្សារក្នុងស្រុកទេ ។ ក្នុងស្ថានភាពបែបនេះភាគច្រើន គឺពួកកសិករជាអ្នកទទួលយកថ្លៃ ហើយពាណិជ្ជករជាអ្នកកំណត់ថ្លៃ ។ ដូច្នេះថ្លៃនៅចំការមានកម្រិតទាប ហើយកសិករទទួលបានប្រាក់ចំណេញតិច ។ ឧបសគ្គដទៃទៀត រួមមាន ការពឹងផ្អែកខ្លាំងលើទឹកភ្លៀង កង្វះខាតអ្នកផ្តល់សេវារៀបចំដីធ្លី ការបិទទ្វារព្រំដែនដែលមិនអាចស្មានដឹង និងលទ្ធភាពតិចតួចក្នុងការខ្ចីបានមីក្រូឥណទានមានការប្រាក់សមរម្យ ។

**ឱកាសល្អ**

គេឃើញមានឱកាសល្អថ្មីៗជាច្រើន សំរាប់កសិករក្នុងការផលិតជ័រឡូងឈើ ។ ទីមួយ ផលិតភាពអាចបង្កើនឡើងទៀតបាន ប្រសិនបើគេអនុវត្តប្រើពូជល្អ និងអាចដោះស្រាយបានកាន់តែប្រសើរនូវបញ្ហាចោទធំៗក្នុងការផលិត ដូចជា កង្វះការយល់ដឹងតិចតួចពីរបៀបប្រើប្រាស់ថ្នាំសម្លាប់ស្មៅ និងការឡើងថ្លៃកត្តាផលិតកម្មផ្សេងៗ ។

ទីពីរ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មអាចជួយបង្កើនផលិតភាពជ័រឡូងឈើ ។ ដូចបានបញ្ជាក់ពីខាងដើម សព្វថ្ងៃនេះគ្មានសេវាផ្សព្វផ្សាយកសិកម្មឡើយ ហើយកសិករដាំជ័រឡូងឈើពឹងផ្អែកតែលើចំណេះដឹងដែលរៀនសូត្របានពីចាស់ទុំ និងពីគ្នាទៅវិញទៅមក ។ ការផ្សព្វផ្សាយពីវិធីល្អសំរាប់ដាំជ័រឡូងឈើដល់កសិករអាចធ្វើបានយ៉ាងស្រួល ដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ។ អន្តរាគមន៍បែបនេះមានប្រយោជន៍ខ្លាំងណាស់ដល់កសិករក្នុងការបង្កើនផលិតភាព និងគុណភាពនៃផលិតផលជ័រឡូងឈើ ។

ទីបី ក្រុមសិក្សាបានសង្កេតឃើញមានដីនៅសល់ទំនេរជាច្រើន ដែលអាចប្រើការបានសំរាប់ពង្រីកផ្ទៃដីដាំដុះ ហើយនៅតំបន់ថ្មីដីមានជីជាតិល្អ ដែលអាចផ្តល់ទិន្នផលបានខ្ពស់ជាង ។

ចំណុចចុងក្រោយគឺ គំនិតផ្តួចផ្តើមជំរុញឱ្យមានសហប្រតិបត្តិការកាន់តែជិតស្និទ្ធ ក្នុងចំណោមបណ្តាប្រទេសនៅមហាអនុតំបន់មេគង្គសំរាប់ផលិតកម្ម និងពាណិជ្ជកម្មជ័រឡូងឈើ អាចផ្តល់ឱកាសល្អដល់កសិករកម្ពុជា ។ ជាការមានប្រយោជន៍ណាស់ ដែលត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស ដូចជា ថៃ និងប្រទេសវៀតណាម ជាដើម ដែលសុទ្ធតែជាប្រទេសនាំចេញជ័រឡូងឈើធំៗបំផុតក្នុងតំបន់ និងមានរបៀបជ្រើសរើសពូជដ៏សមស្រប និងមានវិធីដាំដុះល្អប្រសើរ ។

## ៣.២. កៅស៊ូ

### ៣.២.១ ទិដ្ឋភាពទូទៅនៃផលិតកម្មកៅស៊ូ

តាំងពីយូរមកហើយ កៅស៊ូ គឺជាដំណាំពាណិជ្ជកម្មដ៏ចំបង និងជាប្រភពនាំចេញសំរាប់កម្ពុជា ហើយដោយសារវាជាដំណាំអតិពលកម្ម វាមានសក្តានុពលក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនៅជនបទ ។ តម្លៃបន្ថែមដុល (GVA) នៃកៅស៊ូនៅឆ្នាំ២០០៦ មានប្រមាណ ១០៣,៦១លានដុល្លារអាមេរិក ឬប្រហែល ៥% នៃផលិតកម្មក្នុងវិស័យកសិកម្ម (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៨) ។

ផលិតកម្មកៅស៊ូ បានចាប់ផ្តើមនៅកម្ពុជានៅឆ្នាំ១៩១០ លើផ្ទៃដី ១៥០ហិកតា ដែលជាកម្មសិទ្ធិរបស់លោក Bouillard ជាជនជាតិបារាំង និងដែលផ្តល់ទិន្នផលទាបត្រឹម ២០០ គ.ក្រ/ហិកតា ។ ការដាំកៅស៊ូក្នុងទ្រង់ទ្រាយធំ បានចាប់ផ្តើមនៅឆ្នាំ១៩២១ ដោយក្រុមហ៊ុនធំៗរបស់បារាំង ។ ចាប់ពីពេលនោះមក ទាំងការផលិត និងផលិតភាព បានកើនឡើងរហូតដល់កម្រិតខ្ពស់បំផុតនៅទសវត្សរ៍១៩៦០ ដោយមានផ្ទៃដីដាំដុះ ៥០.០០០ហិកតា និងមានទិន្នផលជិតដល់ ១,៥តោន/ហិកតា ។ ការអូសបន្លាយសង្គ្រាមស៊ីវិលនៅកម្ពុជា បានរាំងស្ទះដល់ការពង្រីកផ្ទៃដីប្រមូលផល ហើយគួបផ្សំនឹងកង្វះការថែទាំ និងកង្វះវិនិយោគ ផលិតភាពបានធ្លាក់ចុះដល់តិចជាងមួយតោនក្នុងមួយហិកតា ។ ទិន្នផលបានកើនឡើងជាបណ្តើរៗវិញ ចាប់ពីទសវត្សរ៍១៩៥០ ដែលសំរេចបានមួយចំណែកដោយសារការកាប់ដើមកៅស៊ូចាស់ៗ និងការចាប់ផ្តើមចៀរជ័រដើមកៅស៊ូក្មេងខ្ចី ។ ខេត្តសំខាន់ៗដែលផលិតកៅស៊ូនៅកម្ពុជា រួមមាន កំពង់ចាម ក្រចេះ កំពង់ធំ និងរតនគិរី ។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF, 2007) ដំណាំកៅស៊ូបានដាំដុះលើផ្ទៃដីចំនួន ៧០.០០០ហិកតា ក្នុងនេះ

៤៤.៨៥០ហិកតា ជារបស់ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនឯកជន ហើយ ២៥.១៥០ហិកតា ជាចំការកៅស៊ូតូចៗរបស់ប្រជាពលរដ្ឋ ។ កម្ពុជាមានចំការកៅស៊ូរបស់រដ្ឋចំនួនប្រាំពីរ ដែលតំណាងឱ្យប្រហែល ៨០% នៃផ្ទៃដីចំការកៅស៊ូសរុប ។ ប៉ុន្តែគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការធ្វើឯកជនភាវូបនីយកម្ម ក្នុងទម្រង់ជាការដកទុនវិនិយោគ បានបង្កើនផ្ទៃដីចំការកៅស៊ូរបស់ក្រុមហ៊ុនឯកជន និងបង្កើនផ្ទៃដីចំការកៅស៊ូតូចៗជាលក្ខណៈគ្រួសារ[4] ។ នៅខែវិច្ឆិកា ឆ្នាំ២០០៨ ក្រុមហ៊ុនចំការកៅស៊ូប្រាំមួយរបស់រដ្ឋ (ពាមជាំង ក្រែក មេមត់ ស្នួល ចំការអណ្តូង និងបឹងកេត) ត្រូវបានធ្វើឯកជនភាវូបនីយកម្ម[5] ។

ចំការកៅស៊ូលក្ខណៈគ្រួសារដែលមានទំហំតូចៗបានកើនឡើងលឿន ដោយសារគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការផ្តល់ចំការកៅស៊ូរដ្ឋមួយផ្នែក ទៅឱ្យកសិករដាំកៅស៊ូដែលបម្រើការឱ្យរដ្ឋាភិបាល ។ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ការអភិវឌ្ឍគម្រោងផលិតកម្មកៅស៊ូលក្ខណៈគ្រួសារ បានប្រព្រឹត្តទៅនៅខេត្តកំពង់ចាម ដែលជាខេត្តមានចំណែកធំបំផុតនៅក្នុងផលិតកម្មកៅស៊ូសរុបនៅកម្ពុជា ។ គម្រោង AFD បានចាប់ផ្តើមនៅឆ្នាំ១៩៩៩ ដោយមានកសិករចូលរួម ៣៤៩គ្រួសារ និងមានផ្ទៃដីដាំដុះជាង ៨៨៧ហិកតា ។ នៅឆ្នាំ២០០៧ ផ្ទៃដីចំការកៅស៊ូគ្រួសារបានកើនឡើងដល់ប្រមាណ ១០.០០០ហិកតា ។ ទោះជាយ៉ាងនេះក្តី យោងតាមអគ្គនាយកដ្ឋានចំការកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំការកៅស៊ូគ្រួសារ ទាំងនៅក្នុង និងនៅក្រៅគម្រោង AFD មានផ្ទៃដីសរុប ៣០.០០០ហិកតា នៅឆ្នាំ២០០៧ ។

**តារាង ៣.៤: កម្មសិទ្ធិគ្រួសារលើដីដាំកៅស៊ូ**

| បរិយាយ | | ពញាក្រែក | មេមត់ |
|---|---|---|---|
| **ទំហំដី** (ហិកតា) | តិចបំផុត | 0.8 | 0.7 |
| | ច្រើនបំផុត | 12.0 | 8.0 |
| | ជាទូទៅ | 3.2 | 2.6 |
| | ជាមធ្យម | 3.5 | 2.1 |
| **ចំនួនប្លង់** | 1 | 9 | 10 |
| | 2 | 7 | 7 |
| | 3 | 3 | 1 |
| | ≥ 4 | 1 | 1 |

*ប្រភព: អង្កេតលើកសិករដាំកៅស៊ូធ្វើឡើងដោយ វិបសអ នៅឆ្នាំ២០០៨*

ម្ចាស់ចំការកៅស៊ូគ្រួសារភាគច្រើនមានចំការកៅស៊ូ ១-២ ប្លង់ ដែលមានផ្ទៃជាមធ្យម ២,៨ហិកតា ។ គ្រួសារនៅស្រុកពញាក្រែក មានទំហំដីធំជាងអ្នកនៅមេមត់ (សូមមើលព័ត៌មានបន្ថែមនៅក្នុងតារាង ៣.៤) ។ ទាក់ទិននឹងកម្មសិទ្ធិភាពដីធ្លី លទ្ធផលអង្កេតបង្ហាញថា កសិករបានទទួលដីតាមបួនមធ្យោបាយផ្សេងៗ គឺរដ្ឋចែកឱ្យ (២២%) រានព្រៃ (៦%) ទិញពីគេ (៣៩%) និងទទួលពីឪពុកម្តាយ និងសាច់ញាតិ (៣៣%) ។ ក្រៅពីនេះ យ៉ាងហោចណាស់ក្នុងអំឡុងពេលសិក្សា មានគ្រួសារ ១៤% មានប័ណ្ណកម្មសិទ្ធិដីធ្លី ៣៨% មានឯកសារ ឬចុងសន្លឹកដែលបានទទួលពីអាជ្ញាធរផ្សេងៗ ៦% កំពុងដាក់ពាក្យសុំកម្មសិទ្ធិ និង ៤២% គ្មានលិខិតស្នាមអ្វីទាំងអស់ ។

---

៤ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការអចិន្ត្រៃយ៍នៅថ្នាក់ជាតិ សំរាប់សម្របសម្រួលឯកជនភាវូបនីយកម្ម និងលើកកំពស់ដំណាំកៅស៊ូ បានអនុម័តឡើងកាលពីខែកញ្ញា ឆ្នាំ១៩៩៤ ។

៥ នាយកដ្ឋានអភិវឌ្ឍន៍ដំណាំកៅស៊ូ/អគ្គនាយកដ្ឋានចំការកៅស៊ូ ។

### ៣.២.២. របៀបរបបដាំដុះ

#### វដ្តជីវិត និងការប្រើប្រាស់ដី

ដើមកៅស៊ូត្រូវការរយៈពេលប្រាំមួយទៅប្រាំពីរឆ្នាំ ទើបចាស់ដើមគ្រប់គ្រាន់អាចផ្តល់ផលបាន ។ ការចៀរជ័រចាប់ផ្តើមនៅឆ្នាំទីប្រាំ ឬទីប្រាំពីរ ក្រោយពេលដាំ ហើយបន្តរហូតដល់អាយុ ២៥ ទៅ ៣០ឆ្នាំ ។ ក្រោយអាយុ ៣០ឆ្នាំ ដើមកៅស៊ូផ្តល់ជ័រកាន់តែបានតិច ធ្វើឱ្យការចៀរជ័រមិនចំណេញ ។ ពេលនោះ គេកាប់ដើមចាស់ និងដាំកូនកៅស៊ូថ្មីជំនួសវិញ (Mead, 2001) ។ តាមធម្មតានៅពេលដើមកៅស៊ូនៅក្មេងខ្ចីនៅឡើយ វាផ្តល់ទឹកជ័រមិនសូវខាប់ទេ ។ នៅពេលដើមកៅស៊ូមានអាយុកាន់តែចាស់ កំហាប់ទឹកជ័រកាន់តែមានកម្រិតខ្ពស់ ។ ដល់ពេលមួយដែលដើមកៅស៊ូចាស់ខ្លាំងពេក ទឹកជ័រក៏ខាប់ខ្លាំងពេកមិនសូវហូរទេ ។ ហេតុនេះ គេមិនអាចចៀរជ័រពីដើមកៅស៊ូចាស់ៗបែបនេះបានឡើយ ។

ដើម្បីឱ្យផលិតភាពនៅស្ថិតស្ថេរ និងឱ្យការប្រើប្រាស់ដីមានមានប្រសិទ្ធភាពល្អ មានគេណែនាំឱ្យអនុវត្តរបៀបដាំដុះមួយផ្សេងទៀតឈ្មោះថា លំនាំដាំដុះជាជួរ ដើម្បីឱ្យមានការផ្ទេរពន្លឺបានច្រើន ដែលអាចបានពេញមួយជីវិតផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនៃដើមកៅស៊ូ ។ លំនាំដាំដើមកៅស៊ូដែលមានគំលាតចន្លោះជួរធំដល់ ១៨ ទៅ ២៥ ម៉ែត្រ ដោយរក្សាដង់ស៊ីតេមានប្រយោជន៍សេដ្ឋកិច្ចនៃដើមកៅស៊ូពី ៤០០ ទៅ ៥០០ដើមក្នុងមួយហិកតា ហើយផ្តល់បរិស្ថានល្អប្រសើរក្នុងរយៈពេលវែងសំរាប់ការបង្កើនមុខដំណាំឱ្យបានកាន់តែច្រើន ។ វិធីនេះទំនងជាមានឥទ្ធិពលខ្លះលើការរីកលូតលាស់ និងលើទិន្នផលនៅចន្លោះជួរ (IRRDB 2001) ។

នៅដំណាក់កាលដំបូង នៅពេលដើមកៅស៊ូមិនទាន់មានស្លឹកច្រើន ហើយពន្លឺព្រះអាទិត្យអាចចាំងចុះដល់ដី កសិករដាំដំណាំរយៈពេលខ្លីសំរាប់លក់យកប្រាក់នៅចន្លោះដើមកៅស៊ូ ។ ក្នុងករណីខ្លះ នៅពេលកសិករដាំកៅស៊ូពុំមានលទ្ធភាពដាំដំណាំបន្ទាប់បន្សំនៅក្នុងចំការកៅស៊ូបាន ពួកគេអនុញ្ញាតឱ្យអ្នកភូមិផងគ្នាដាំដំណាំនៅចន្លោះដើមកៅស៊ូ ដោយយកថ្លៃឈ្នួលដីប្រហែល ៥០ដុល្លារក្នុងមួយហិកតាក្នុងមួយឆ្នាំ ។ ពួកគេគ្រាន់តែព្រមព្រៀងគ្នាផ្ទាល់មាត់ ដែលតាមធម្មតាអាស្រ័យលើទំនុកចិត្ត ផលប្រយោជន៍ទាំងសងខាង និងសមាណចិត្តរបស់ម្ចាស់ចំការកៅស៊ូ ចំពោះគ្រួសារក្រីក្រដែលគ្មានដីធ្លី ។ ដំណាំដែលគេនិយមដាំជាងគេលើដីចំការកៅស៊ូកាលពីឆ្នាំមុនគឺ ដំឡូងឈើ ហើយនៅឆ្នាំ២០០៨ ខាងមុខនេះ ក៏ទំនងជាមានការដាំដុះដូច្នេះទៀត ដោយសារគេរំពឹងថា ដំឡូងឈើនឹងមានថ្លៃល្អ ។

ការដាំដំណាំដទៃទៀតក្នុងចំការកៅស៊ូ អាចបន្តរហូតដល់បីទៅបួនឆ្នាំ គឺមុនពេលដើមកៅស៊ូមានស្លឹកច្រើន ហើយមានម្លប់ខ្លាំងលើផ្ទៃដី ។ ទោះបីជាចំណូលពីដំណាំមិនមែនកៅស៊ូមានចំនួនមិនច្រើនក្តី ក៏វាជួយសម្រាលចំណាយជាប្រចាំលើចំការកៅស៊ូនោះដែរ ។ យោងតាមកិច្ចពិភាក្សាជាមួយក្រុមគោលដៅ ការឡើងថ្លៃស្បៀងអាហារនៅគ្រប់ទីកន្លែងក្នុងឆ្នាំនេះ អាចទាក់ទាញប្រជាពលរដ្ឋកាន់តែច្រើនឱ្យដាំដំណាំលក់យកប្រាក់ នៅក្នុងចំការដែលមានដើមកៅស៊ូនៅក្មេង ។

#### កត្តាផលិតកម្មកសិកម្ម

នៅក្នុងតំបន់ធ្វើការសិក្សា គេដាំពូជកៅស៊ូមួយចំនួន ។ ពូជដែលគេនាំចូល និងប្រើប្រាស់នៅកម្ពុជា ជាយូរណាស់មកហើយ គឺពូជ GT1 ដែលជាពូជពេញនិយមបំផុត ហើយបន្ទាប់មក គឺពូជ PBM ។ ម្ចាស់ចំការកៅស៊ូគ្រួសារប្រហែលពាក់កណ្តាល ទិញកូនកៅស៊ូពីក្រុមហ៊ុនផ្សេងៗ ហើយពាក់កណ្តាលទៀតមិនអាចធ្វើបែបនេះបានទេ ដូច្នេះត្រូវប្រើគ្រាប់ពូជជាច្រើនចម្រុះគ្នាដែលប្រមូលបានមកពីកសិដ្ឋានចំការកៅស៊ូឯទៀតៗ ។ តាមវិធីនេះ គេចំណាយប្រាក់អស់តិចជាង ប៉ុន្តែទិន្នផលក៏ទាបជាងការទិញពូជពីក្រុមហ៊ុនដែរ ។

**តារាង ៣.៥: ប្រភេទពូជកៅស៊ូកំពុងប្រើ**

| | ពូជកៅស៊ូ | | | | | | សរុប |
|---|---|---|---|---|---|---|---|
| | GT1 | PB260 | RA4 | RA5 | PBM | * | |
| ចំនួនប្លង់ | 29 | 1 | 1 | 1 | 3 | 34 | 69 |
| ភាគរយ | 42.0 | 1.4 | 1.4 | 1.4 | 4.3 | 49.3 | 100 |

*  *សំដៅដល់ពូជដែលបានប្រើ ប៉ុន្តែកសិករមិនអាចបញ្ជាក់បានដោយសារប្រើពូជចម្រុះ ។ តាមធម្មតា ពួកគេជាកសិករក្រីក្រដែលមិនអាចទិញពូជសុទ្ធពីក្រុមហ៊ុនបាន ។*

*ប្រភព: អង្កេតរបស់ វិបសអ ឆ្នាំ២០០៨ អំពីកសិករដាំកៅស៊ូ*

ជាទូទៅ ភាគច្រើនគេប្រើពលករជាសមាជិកគ្រួសារក្នុងដំណើរការផលិតកម្ម ក្នុងនោះមានការរៀបចំដីរហូតដល់ការដាំដុះ និងការប្រមូលផល ។ គេក៏ជួលពលករឱ្យប្រមូលផលផងដែរ ពិសេសសំរាប់គ្រួសារដាំកៅស៊ូដែលពុំមានកម្លាំងពលកម្មគ្រួសារគ្រប់គ្រាន់ ។ កសិករប្រើជីគីមីច្រើនជាងជីសរីរាង្គ ហើយភាគច្រើនគេដាក់ជីនៅពេលដាំកូនកៅស៊ូ ហើយដាក់ជីម្តងទៀតនៅពេលមួយឆ្នាំមុននឹងចាប់ផ្តើមប្រមូលផល ។

ឧបករណ៍សំខាន់ៗសំរាប់ប្រមូលផល រួមមាន ចានត្រងជ័រ ធុងធំៗចំណុះ ៣០លីត្រមួយចំនួន និងកូនកាំបិត ឬពន្លាកពិសេស ។ គេប្រើពន្លាកសំរាប់ឆ្កូតសំបកឈើដើម្បីធ្វើឱ្យដាច់ផ្លូវហូរជ័រ ដោយមិនធ្វើឱ្យដាច់ស្រទាប់ទន់ស្ថិតនៅចន្លោះសំបក និងតួដើមកៅស៊ូឡើយ ។ កម្មករភាគច្រើនដែលគេជួលឱ្យចៀរជ័រ ទទួលបានប្រាក់ឈ្នួលប្រចាំខែ ហើយមានកម្មករតិចតួចប៉ុណ្ណោះ ដែលគេផ្តល់ប្រាក់ប្រចាំថ្ងៃ ។ ក្រៅពីប្រាក់ដែលម្ចាស់ចំការកៅស៊ូផ្តល់ឱ្យ កម្មករស៊ីឈ្នួលក៏អាចប្រមូលជ័រនៅសេសសល់ក្នុងចានជ័រ ដែលធ្វើឱ្យពួកគេរកចំណូលបន្ថែមបានខ្លះទៀត ។

### ការប្រមូលផល

ក្នុងវដ្តចៀរជ័រមួយឆ្នាំ ធាតុអាកាសនៅក្នុងចំការកៅស៊ូផ្លាស់ប្តូររវៀងរាល់ពីរទៅបីខែម្តង ដែលធ្វើឱ្យប៉ះពាល់ដល់សរីរសាស្ត្រនៃដើមកៅស៊ូ ។ បម្រែបម្រួលនេះធ្វើឱ្យប៉ះពាល់ដល់កំហាប់ និងទិន្នផលទឹកជ័រ ។ នៅពេលមានភ្លៀងធ្លាក់តិចតួចក្នុងដីមានជាតិទឹកតិចតួច ហើយសំបកដើមកៅស៊ូនៅតែមានសភាពរឹង និងរក្សាជាតិទឹកបានតិចតួចដែរ ។ ប្រការនេះធ្វើឱ្យទឹកជ័រមានកំហាប់ខ្ពស់ ដែលធ្វើឱ្យទឹកជ័រហូរយឺត ហេតុនេះគេក៏ត្រងទឹកជ័របានតិច ។ រឿងនេះមានន័យថា ដើមកៅស៊ូដែលគេបង្កាត់ជាមួយពូជមានទឹកជ័រមានកំហាប់ខ្ពស់ វាផ្តល់ទិន្នផលទាប ប៉ុន្តែដើមកៅស៊ូដែលគេបង្កាត់ជាមួយពូជមានកំហាប់ទឹកជ័ររាវ វាផ្តល់ទិន្នផលខ្ពស់ជាង ។

នៅពាក់កណ្តាលរដូវភ្លៀង នៅពេលដែលមានភ្លៀងធ្លាក់ច្រើន ដីចាប់ផ្តើមឆ្អែតដោយជាតិទឹក សំបកដើមកៅស៊ូចាប់ផ្តើមប្រែជាមានសភាពទន់ ហើយកំហាប់ទឹកជ័រក៏ថយចុះ ។ នៅពេលទឹកជ័រមានកំហាប់រាវ វាអាចហូរបានយូរជាង ហើយទិន្នផលក៏បានច្រើនជាង ។ កៅស៊ូដែលបង្កាត់ជាមួយពូជមានកំហាប់ទឹកជ័រខ្ពស់ វាផ្តល់ទិន្នផលបានតិចជាងកៅស៊ូដែលបង្កាត់ជាមួយពូជមានកំហាប់ទឹកជ័ររាវ ។ នៅពេលទឹកភ្លៀងចាប់ផ្តើមថយចុះ ហើយខ្យល់ត្រជាក់ក៏បក់មកពាសពេញ ភាពត្រជាក់ធ្វើឱ្យទឹកជ័រកកយឺត ដូច្នេះវាហូរបានកាន់តែយូរ ។

នៅចុងរដូវភ្លៀង ដីចាប់ផ្តើមស្ងួត ស្លឹកកៅស៊ូចាប់ផ្តើមជ្រុះ ពន្លឺព្រះអាទិត្យក៏អាចចាំងចុះច្រើនមកដល់ដី ហើយសីតុណ្ហភាពនៅក្នុងចំការកៅស៊ូក៏កើនឡើង ។ អាកាសធាតុបែបនេះ ធ្វើឱ្យទឹកជ័រហូរកាន់តែយឺត ហើយទិន្នផលក៏ធ្លាក់ចុះ ។ ក្នុងករណីនេះ

ដើមកៅស៊ូដែលបង្កាត់ជាមួយពូជមានកំហាប់រាវ វាផ្តល់ទិន្នផលបានខ្ពស់ជាង រីឯដើមកៅស៊ូដែលបង្កាត់ជាមួយពូជមានកំហាប់ខាប់ វាផ្តល់ទិន្នផលបានតិចជាង ។

គេបានកត់សម្គាល់ថា សីតុណ្ហភាពក៏ប៉ះពាល់ដល់ទិន្នផលដែរ ពីព្រោះនៅពេលមានសីតុណ្ហភាពខ្ពស់ ទឹកជ័រមិនហូរឡើយ ។ នៅតំបន់មានសីតុណ្ហភាពខ្ពស់ ពូជកៅស៊ូដែលមានកំហាប់ទឹកជ័ររាវ មិនសូវរងផលប៉ះពាល់ដូចពូជដែលមានកំហាប់ទឹកជ័រខាប់ឡើយ ។ កម្មករគួរចៀរជ័រតាំងពីព្រលឹម នៅពេលដែលដីនៅត្រជាក់ ដើម្បីបានទទួលទឹកជ័រច្រើន ។ ជាទូទៅដើមកៅស៊ូអាចផលិតទឹកជ័របានច្រើននៅតាមតំបន់ដែលមានរដូវត្រជាក់វែង និងមានរដូវរាំងស្ងួតខ្លី ។

តាមធម្មតា កសិករប្រមូលផលតែមួយដង ពីស្នាមចៀរមួយនៅលើផ្ទៃដើមកៅស៊ូ ។ នៅពេលកៅស៊ូឡើងថ្លៃ កសិករប្រមូលទឹកជ័រពីរដង ពីស្នាមចៀរពីរនៅលើដើមកៅស៊ូ ។ ទោះជាយ៉ាងនេះក្តី លទ្ធផលអង្កេតបង្ហាញថា មានកសិករត្រឹមតែ ៣០% ប៉ុណ្ណោះ ដែលប្រមូលផលពីរដង នៅពេលកៅស៊ូឡើងថ្លៃ ។ ជាទូទៅគេចៀរជ័រ ២-៣ ថ្ងៃម្តង ប៉ុន្តែការឡើងថ្លៃកៅស៊ូអាចជំរុញឱ្យកសិករចៀរជ័រកាន់តែញឹកញាប់ ។ ក្នុងអំឡុងពេលអង្កេត នៅពេលដែលថ្លៃកៅស៊ូមានកម្រិតខ្ពស់ កសិករភាគច្រើន (៦៤%) ធ្វើការចៀរជ័រចន្លោះ ២-៣ថ្ងៃម្តង ហើយក្រៅពីនេះគេព្យាយាមចៀរជ័ររៀងរាល់ថ្ងៃ ។

### ៣.២.៣. ចំណាយផលិតកម្ម

ដំណាំកៅស៊ូតម្រូវឱ្យមានការវិនិយោគជាច្រើនឆ្នាំជាប់រហូត ដោយគ្មានទទួលចំណូលហិរញ្ញវត្ថុអ្វីមកវិញទេ រហូតទាល់តែដល់ពេលចាប់ផ្តើមចៀរជ័រ ។ ចំណូលហិរញ្ញវត្ថុមុនពេលចៀរជ័រ បានជាសំខាន់មកពីផលិតកម្មដំណាំលក់យកប្រាក់ ឬថ្លៃជួលដីឱ្យកសិករដាំដំណាំសំរាប់លក់ ។ ចំណូលបានមកពីដំណាំទាំងនោះ ឬបានមកពីថ្លៃឈ្នួលដី មិនត្រូវបានដាក់បញ្ចូលក្នុងការគណនាថ្លៃដើមនៅក្នុងការសិក្សានេះទេ ប៉ុន្តែគេអាចគិតបញ្ចូលបានយ៉ាងងាយ ដោយបូកបន្ថែមទឹកប្រាក់ ៥០ដុល្លារអាមេរិកក្នុងមួយហិកតាក្នុងមួយឆ្នាំ (សូមមើលការពន្យល់ក្នុងរបៀបរបបដាំដុះនៅខាងលើ) ។ បាតុភាពសំខាន់មួយដែលបានកើតឡើងកាលក្នុងប៉ុន្មានឆ្នាំថ្មីៗ គឺការឡើងថ្លៃដីយ៉ាងលឿន ។ ដីចំការកៅស៊ូភាគច្រើន ជាពិសេសដីនៅជាប់ផ្លូវថ្នល់ធំៗ ឡើងថ្លៃដល់ប្រមាណ ២០.០០០ដុល្លារក្នុងមួយហិកតា ខណៈពេលដែលដីឯទៀតមានតម្លៃត្រឹម ៥០០០ ទៅ ១៥.០០០ដុល្លារក្នុងមួយហិកតាប៉ុណ្ណោះ ។

កត្តាផលិតកម្មសំខាន់ៗក្នុងផលិតកម្មកៅស៊ូ រួមមាន ដី ពលកម្ម និងទុន ។ តម្លៃពលកម្មកំពុងកើនឡើងរហូតដល់ត្រូវចំណាយ ២-២,៥ដុល្លារសំរាប់កម្មករមួយនាក់ក្នុងមួយថ្ងៃ រឺប្រហែល ៣០% ខ្ពស់ជាងកាលពីប៉ុន្មានឆ្នាំមុន ។ ប្រការនេះបណ្តាលមកពីកំណើនឱកាសការងារកសិកម្ម និងមិនមែនកសិកម្ម សំរាប់អ្នកភូមិ ទាំងនៅក្នុង និងនៅក្រៅតំបន់សិក្សា ។ នៅដើមឆ្នាំ២០០៨ នៅពេលត្រូវប្រមូលផលដំឡូងឈើ មានការប្រកួតប្រជែងដណ្តើមកម្លាំងពលកម្មជាខ្លាំង ធ្វើឱ្យថ្លៃពលកម្មកើនឡើង ។ អតិផរណាខ្ពស់ ក៏បង្កឱ្យមានការទាមទារប្រាក់ឈ្នួលពលកម្មខ្ពស់ជាទូទៅដែរ ។

ពលកម្ម គឺជាមុខចំណាយចំបងគេ ហើយវាប្រែប្រួលតាំងពីឆ្នាំទីមួយរហូតដល់ពេលប្រមូលផល ។ ពលកម្មត្រូវប្រើប្រាស់យ៉ាងច្រើនក្នុងការរៀបចំដី ការដាំដុះ និងការចៀរជ័រ ។ យោងតាមលទ្ធផលអង្កេត កសិករត្រូវចំណាយលើពលកម្មជាមធ្យមប្រហែល ៧០% នៃចំណាយផលិតកម្មសរុប ។

កង្វះកម្លាំងពលកម្មមានជំនាញចៀរជ័រជាបញ្ហាមួយធ្ងន់ធ្ងរ ហើយអាចបង្កការខាតបង់យ៉ាងច្រើន ដោយសារនៅសល់ដើមកៅស៊ូដែលគ្មានអ្នកចៀរជ័រ ។ ការជួលអ្នកចៀរជ័រគ្មានជំនាញ អាចធ្វើឱ្យខូចស្រទាប់ទន់នៅចន្លោះដើមនិងសំបកកៅស៊ូ និងធ្វើឱ្យមានអត្រារលាត់សំបកកៅស៊ូកើតខ្ពស់ ។ ការខូចខាតដល់ស្រទាប់ទន់ និងអត្រារលាត់សំបកកៅស៊ូកើតខ្ពស់ ធ្វើឱ្យប៉ះពាល់ដល់ល្បឿននៃការដុះសំបកថ្មី ។ នៅពេលគេចៀរជ័រលើសំបកដែលដុះថ្មីមិនបានត្រឹមត្រូវនេះ ទិន្នផលនឹងធ្លាក់ចុះ ។

តាមធម្មតា គេប្រមូលទឹកជ័រនៅក្នុងចានត្រងជ័រ ។ គេអាចលក់ទឹកជ័រដែលប្រមូលបែបនេះនៅថ្ងៃដដែល ។ សំរាប់ចំការកៅស៊ូមួយចំនួនដែលស្ថិតនៅឆ្ងាយពីទីផ្សារ កសិករបង្កកទឹកជ័រ ហើយរង់ចាំឈ្មួញមកប្រមូលទិញ ។ វិធីសាស្ត្រប្រមូលផលដោយបង្កកជាដុំៗបែបនេះ ជួយកាត់បន្ថយភាពញឹកញាប់នៃការប្រមូលផលប្រហែលមួយសប្តាហ៍ អាស្រ័យលើចំនួនផលដែលត្រូវប្រមូលនៅកន្លែងនីមួយៗ ។ ការថយចុះចំណាយពលកម្ម និងកំណើនផលិតភាព អាចសំរេចបានតាមរយៈការប្រើវិធីប្រមូលផលត្រឹមត្រូវ គួបផ្សំជាមួយនឹងការពង្រីកទំហំភារកិច្ច ការប្រើសារធាតុរំញោចទឹកជ័របានសមស្រប និងការប្រើឧបករណ៍ការពារទឹកភ្លៀង ។

ចំពោះការចំណាយលើសម្ភារៈផលិតកម្មវិញ ការទិញកូនកៅស៊ូជាមុខចំណាយធំបំផុតនៅឆ្នាំទីមួយ ។ ចំណាយលើសម្ភារៈ ផលិតកម្មអាចកើនខ្ពស់មួយកម្រិតទៀត បើសិនកសិករដាំកៅស៊ូទាំងអស់គ្នាត្រូវទិញកូនកៅស៊ូពីក្រុមហ៊ុន (ដូចមានចុះក្នុងតារាង ៣.៦ មានកសិករតែ ៥០% ប៉ុណ្ណោះ ដែលទិញកូនកៅស៊ូ) ។ យោងតាមលទ្ធផលអង្កេតនេះ ចំណាយសរុបលើដំណាំកៅស៊ូឡើងដល់ ៤៣៩ដុល្លារនៅឆ្នាំទីមួយ ហើយធ្លាក់ចុះជាបណ្តើរៗមកត្រឹម ២០៩ដុល្លារនៅឆ្នាំទីប្រាំមួយ ។ ជាមធ្យម ចំណាយនេះកើនឡើងរហូតដល់ ៥៨០ដុល្លារ នៅពេលចាប់ផ្តើមប្រមូលផល ។ តាមការប៉ាន់ស្មាន ចំណាយផលិតកម្មសរុបគឺ ១.៧១៤ដុល្លារក្នុងមួយហិកតា ចាប់ពីឆ្នាំទីមួយដល់ឆ្នាំទីប្រាំមួយ មុនពេលដើមកៅស៊ូផ្តល់ជ័រ ។

**តារាង ៣.៦: ចំណាយផលិតកម្មកៅស៊ូនៅមេមត់ និងពញាក្រែក ឆ្នាំ២០០៧ (គិតជាដុល្លារអាមេរិកក្នុងមួយហិកតា)**

| | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | ឆ្នាំទី ៦ | ឆ្នាំទី ៧ |
|---|---|---|---|---|---|---|---|
| ការរៀបចំដី | 245 | 152 | 121 | 85 | 115 | 42 | 46 |
| ការថែទាំ | 49 | 36 | 81 | 72 | 74 | 71 | 87 |
| ការប្រមូលផល | - | - | - | - | - | - | 379 |
| សម្ភារៈផលិតកម្ម | 132 | 74 | 74 | 116 | 49 | 95 | 63 |
| ផ្សេងៗ | 13 | 15 | - | - | - | - | 5 |
| សរុប | 439 | 277 | 277 | 273 | 238 | 209 | 580 |

*សំគាល់: ថ្លៃឈ្នួលដីមិនត្រូវបានបូកបញ្ចូលក្នុងការគណនាឡើយ*

*ប្រភព: អង្កេតឆ្នាំ២០០៨ របស់ វិបសអ លើកសិករដំណាំកៅស៊ូ*

ដោយសារការដាំដុះពូជកៅស៊ូផ្តល់ទិន្នផលខ្ពស់ និងការប្រើវិធីសាស្ត្រកាន់តែមានប្រសិទ្ធិភាព ក្នុងការបង្កើនទិន្នផល គេរំពឹងថា ទឹកជ័រនឹងហូរបានកាន់តែយូរ ជាពិសេសនៅតាមកន្លែងដែលគេចៀរជ័រមិនសូវញឹកញាប់ ។ នៅកន្លែងខ្លះ គេគួរប្រមូលផលទ្វេដងដោយសារការហូរជ័រមានរយៈពេលវែង ។ មុនពេលកាប់ដើម កសិករត្រូវប្រើសារធាតុគីមីដើម្បីបង្កើនផលិតកម្ម ដែលជាការយកឱ្យអស់លទ្ធភាពជាចុងក្រោយ ។ ម្ចាស់ចំការមួយចំនួនចង់អនុវត្តការប្រមូលទ្វេដង និងវិធីជំរុញកំណើនទិន្នផល នៅពេលកៅស៊ូមានថ្លៃខ្ពស់ ។ ពួកគេដឹងថា វិធីនេះធ្វើឱ្យដើមកៅស៊ូឆាប់អស់ជ័រជាងវិធីប្រមូលផលតាមធម្មតា ។

### ៣.២.៤ សក្តានុពល និងគោលនយោបាយ

ដំណើរការសមាហរណកម្មសេដ្ឋកិច្ចរបស់កម្ពុជាមានលក្ខណៈជ្រាលជ្រៅ ដោយសារកម្ពុជាចូលក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅឆ្នាំ១៩៩៩ និងការប្តេជ្ញាគោរពតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មប្រចាំតំបន់ និងប្រព័ន្ធពាណិជ្ជកម្មពិភពលោកជាទូទៅ ។ គិតត្រឹមខែកក្កដា ឆ្នាំ២០០៨ ប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចំនួនបី ហើយកំពុងចរចាកិច្ចព្រមព្រៀងចំនួនប្រាំទៀត (ADB 2008) ។ កិច្ចព្រមពៀងពាណិជ្ជកម្មសេរីដំបូងគេរបស់កម្ពុជាគឺ កិច្ចព្រមព្រៀងស្តីពីតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ដែលត្រូវអនុវត្តក្រោយពេលចូលជាសមាជិកភាពអាស៊ាននៅឆ្នាំ១៩៩៩ ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្រោយៗមកទៀត ត្រូវបានចរចា និងកំពុងចរចា រវាងប្លុកអាស៊ានជាមួយនឹងប្រទេសចិន កូរ៉េ ជប៉ុន ឥណ្ឌា អូស្ត្រាលី និង ណូវែលហ្សេឡង់ ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងនេះ បង្កលក្ខណៈឱ្យប្រទេសកម្ពុជាទទួលបានលក្ខខណ្ឌអនុគ្រោះបន្ថែមទៀតសំរាប់ការនាំចេញផលិតផលកៅស៊ូរបស់ខ្លួនចូលទៅកាន់ទីផ្សារធំៗ ។ ឧទាហរណ៍ ចិនជាប្រទេសមួយដែលប្រើប្រាស់កៅស៊ូច្រើនបំផុត ហើយការបញ្ចុះអត្រាពន្ធនាំចូលលើផលិតផលកៅស៊ូ ដែលអនុវត្តតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន-ចិន នឹងជួយជំរុញការនាំចេញបន្ថែមទៀតពីប្រទេសកម្ពុជា ហេតុនេះនឹងធ្វើឱ្យផលិតកម្មកៅស៊ូនៅកម្ពុជាកើនឡើង ។ ជាផ្លូវដើរទៅអនាគត កម្ពុជាគួរបង្កើនគុណភាពនៃការកែច្នៃកៅស៊ូឱ្យឡើងដល់កម្រិត ស្របតាមតម្រូវការទីផ្សារប្រទេសចិន ព្រមទាំងឱ្យផលិតផលកៅស៊ូរបស់ខ្លួនមានថ្លៃប្រកួតប្រជែងល្អផង ។

### ៣.២.៥. ឧបសគ្គ និងឱកាស

តាមឯកសាររបស់ Burger and Smith (2001) សេដ្ឋកិច្ចរបស់តួអង្គសំខាន់ៗនៅក្នុងទីផ្សារកៅស៊ូធម្មជាតិ ទាំងខាងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ បានរងគ្រោះយ៉ាងធ្ងន់ធ្ងរពីវិបត្តិហិរញ្ញវត្ថុអាស៊ី ។ វិបត្តិនេះនាំឱ្យមានការវិវត្តច្របូកច្របលនៅក្នុងទីផ្សារកៅស៊ូធម្មជាតិ តាំងពីពេលកំពុងកើតវិបត្តិរហូតដល់ឆ្នាំ២០០០ ។ រហូតមកដល់ពេលថ្មីៗនេះ ដែលថ្លៃកៅស៊ូចាប់កើនឡើងវិញ កសិករមានអារម្មណ៍បាក់ទឹកចិត្ត ដោយសារការធ្លាក់ថ្លៃកាលពីមុន ។ ចំការកៅស៊ូត្រូវការការវិនិយោគក្នុងរយៈពេលវែង ហើយដោយហេតុថា កសិករកម្ពុជាគ្រាន់តែជាអ្នកទទួលយកតាមថ្លៃទីផ្សារ ដូច្នេះពួកគេងាយរងគ្រោះពីការឡើងចុះថ្លៃកៅស៊ូ ជាពិសេសកសិករមានចំការតូចៗ ។

ទោះជាកម្ពុជាបើកចំហចំពោះពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេសក្តី អាជីវកម្មមួយចំនួន (ទាំងរបស់អ្នកក្នុងស្រុក និងរបស់ជនបរទេស) បានរាយការណ៍ថា កំពុងចាញ់ប្រៀបគូប្រជែងក្នុងស្រុក ឬគូប្រជែងបរទេសទាំងឡាយ ដែលចូលរួមប្រព្រឹត្តអំពើពុករលួយ ឬគេចមិនបង់ពន្ធ ឬឆក់ឱកាសគេងចំណេញពីការអនុវត្តបញ្ញត្តិច្បាប់នៅកម្ពុជាមិនទាន់បានល្អ[៦] ។ ស្ថានភាពបែបនេះ ធ្វើឱ្យក្រុមហ៊ុនធំៗមួយចំនួនឆក់ឱកាសយកប្រៀបឈ្នះ និងធ្វើការត្រួតត្រាលើវិស័យកៅស៊ូនៅកម្ពុជា ។

យោងតាមទ្រឹស្តីតម្រូវការ និងការផ្គត់ផ្គង់ ទិន្នផលខ្ពស់នៃផលិតផលកសិកម្មនៅប្រទេសណាមួយ ជួយឱ្យប្រទេសនោះអាចលក់ផលិតផលកសិកម្មដោយយកថ្លៃថោកជាង ។ ប៉ុន្តែសំរាប់កម្ពុជាពុំមែនដូច្នេះឡើយ ពីព្រោះភាពបើកចំហ និងកិច្ចសម្រួលពាណិជ្ជកម្មរបស់កម្ពុជា បានផ្សារភ្ជាប់ថ្លៃក្នុងស្រុកជាមួយនឹងថ្លៃនៅទីផ្សារអន្តរជាតិ ។ ហេតុនេះ ថ្លៃទំនិញកសិផលបានកើនឡើងស្របជាមួយថ្លៃក្នុងតំបន់ និងថ្លៃអន្តរជាតិ ពិសេសនៅដើមឆ្នាំ២០០៨ នៅពេលដែលថ្លៃកៅស៊ូស្ទុះឡើងយ៉ាងខ្ពស់ ។ ថ្លៃខ្ពស់នៃប្រេងឥន្ធនៈ ក៏ធ្វើឱ្យផលិតកម្មកៅស៊ូសំយោគជួបការលំបាកដែរ ។ ទោះជាយ៉ាងនេះក្តី ដោយសារទំនិញកសិផលទាំង

៦ សៀវភៅមគ្គុទេសក៍ពាណិជ្ជកម្មកម្ពុជា ឆ្នាំសារពើពន្ធ ២០០៦ ។

អស់នៅតែមានថ្លៃខ្ពស់ ហើយកៅស៊ូនៅតែមានគេត្រូវការនៅក្នុងផលិតកម្មសំបកកង់រថយន្ត ដូច្នេះផលិតករកៅស៊ូនៅតែមានអនាគតភ្លឺថ្លា យ៉ាងហោចណាស់ក៏សំរាប់ប៉ុន្មានឆ្នាំខាងមុខនេះដែរ ។

កន្លងមកនេះ សេវាគាំទ្រ ឬអន្តរាគមន៍ពីក្រសួងមន្ទីរពាក់ព័ន្ធហាក់ដូចមិនសូវឃើញមានផ្តល់ច្រើនទេ ។ ការស្រាវជ្រាវ និងសកម្មភាពផ្សព្វផ្សាយ វាមានប្រសិទ្ធភាពកាន់តែខ្ពស់ ដោយសារមានការចូលរួមពីវិស័យឯកជន ដែលធ្វើឱ្យមានការផ្លាស់ប្តូរបច្ចេកទេសកសិកម្មក្នុងចំណោមពួកកសិករ ។ ម្យ៉ាងទៀត បញ្ហាទីផ្សារក៏មិនសូវចោទដូចកាលពីមុនដែរ ដោយសារមានតម្រូវការទំនិញកសិកម្មខ្ពស់ មានការកែលំអ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកិច្ចសម្រួលពាណិជ្ជកម្ម ។

កសិកម្មកម្ពុជាសម្លឹងឃើញសក្តានុពលក្នុងការបង្កើនផលិតកម្ម និងឱកាសល្អក្នុងការពង្រីកចំណូលពីការលក់ ។ កសិកម្មជាមូលដ្ឋាននៃការអភិវឌ្ឍជនបទ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ប៉ុន្តែគួរឱ្យសោកស្តាយក្នុងពេលកន្លងទៅវាមានកំណើនតិចតួច ដោយសារទឹកជំនន់ ភាពរាំងស្ងួត និងបញ្ហាជាប់ទាក់ទងនឹងការកើតមានជម្ងឺ និងសត្វល្អិតបំផ្លាញ ។ ទោះជាយ៉ាងនេះក្តី ក្នុងប៉ុន្មានឆ្នាំថ្មីៗអាកាសធាតុអំណោយផលល្អជាងមុនសំរាប់កសិកម្មនៅកម្ពុជា ។ ខេត្តមួយចំនួន ដូចជា កំពង់ស្ពឺ ស្វាយរៀង ព្រៃវែង និង កំពង់ធំ ដែលតែងជួបគ្រោះរាំងស្ងួតនៅពាក់កណ្តាល ឬនៅចុងរដូវ អាចបានធូរធារថែមទៀត ប្រសិនបើងាកមកដាំកៅស៊ូ ជាជាងដាំដំណាំកសិកម្មធម្មតា ។

ជាទូទៅមិនសូវមាន ឬក៏គ្មានការរើសអើង ចំពោះវិនិយោគិនបរទេសឡើយ ទោះជាក្នុងអំឡុងពេលដំបូងនៃការវិនិយោគ ឬក្រោយពេលវិនិយោគក្តី ។ ច្បាប់កម្ពុជាស្តីពីការវិនិយោគឆ្នាំ១៩៩៤ បានបង្កើតរបបវិនិយោគមួយបើកចំហ និងមានលក្ខណៈសេរី ដែលអនុញ្ញាតឱ្យពលរដ្ឋកម្ពុជា និងជនបរទេស ចូលធ្វើ រឺចេញវិញ ពីវិនិយោគក្នុងវិស័យទាំងឡាយនៃសេដ្ឋកិច្ចដោយសេរី ។ ភាពជាម្ចាស់កម្មសិទ្ធិទាំងស្រុងត្រូវបានអនុញ្ញាតស្ទើរតែគ្រប់វិស័យ លើកលែងតែដីធ្លីចេញ ។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញចែងថា មានតែពលរដ្ឋកម្ពុជា និងអង្គភាពនីតិបុគ្គលប៉ុណ្ណោះ ដែលមានសិទ្ធិមានកម្មសិទ្ធិដីធ្លី[៧] ។ គោលនយោបាយវិនិយោគ ដែលមានលក្ខណៈសេរីរបស់កម្ពុជា ពិតជាអាចទាក់ទាញវិនិយោគបរទេសច្រើនថែមទៀតក្នុងពេលអនាគត ។

---

៧ សៀវភៅមគ្គុទេសក៏ផ្នែកពាណិជ្ជកម្មនៅកម្ពុជា ឆ្នាំសារពើពន្ធ ២០០៦ ។ សូមអានផងដែរនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើវិសោធនកម្ម ។

# ជំពូកទី ៤. ពាណិជ្ជកម្ម

## ៤.១. ពាណិជ្ជកម្មជ័រទឹកឈើ

### ៤.១.១. ខ្សែរយៈទីផ្សារ

ពាណិជ្ជកម្មជ័ទ្បូងឈើពាក់ព័ន្ធជាមួយតួអង្គជាច្រើន រួមមាន កសិករ អ្នកប្រមូលទិញ ឈ្មួញ ភ្នាក់ងាររោងចក្រ និងរោងចក្រកែច្នៃ ។ ដូចមានបង្ហាញក្នុងគំនូសតាងខាងក្រោម (ក្រាហ្វិក ៤.១) ខ្សែរយៈទីផ្សារនៃជ័ទ្បូងឈើដើរតួជាអន្តរការីចំបងក្នុងចំណោមកសិករ និងរោងចក្រកែច្នៃ ។ ឈ្មួញបរទេស ក៏ដើរតួសំខាន់ក្នុងពាណិជ្ជកម្មជ័ទ្បូងឈើនៅកម្ពុជាដែរ ដោយពួកគេទិញជ័ទ្បូងឈើយ៉ាងច្រើន ដើម្បីលក់បន្តទៅឱ្យរោងចក្រកែច្នៃនៅប្រទេសរបស់ពួកគេ ។ ដោយសារក្រុមស្រាវជ្រាវជួបការលំបាកមួយចំនួនក្នុងការធ្វើទំនាក់ទំនងជាមួយឈ្មួញក្នុងស្រុក និងឈ្មួញបរទេស ការវិភាគភាគីពាក់ព័ន្ធខាងក្រោមនេះផ្តោតលើតួអង្គសំខាន់បី គឺ កសិករ អ្នកប្រមូលទិញ និងឈ្មួញ ។

#### កសិករ

កសិករមានជម្រើសតិចតួចក្នុងការលក់ផលជ័ទ្បូងឈើរបស់ខ្លួន ។ជម្រើសសមស្របរបស់ពួកគាត់ផ្អែកលើកត្តាជាច្រើន ដូចជា ចំណូលរំពឹងទុក ចំណាយផ្សេងៗ និងធនធានដែលមាន ។ របៀបលក់ប្រែប្រួលខុសគ្នារវាងភាគខាងលិច និងភាគខាងកើត ហើយជម្រើសផ្សេងៗមានរៀបរាប់សង្ខេបដូចខាងក្រោម ។ តួលេខខាងក្រោមនេះ ផ្អែកលើលទ្ធផលអង្កេតឆ្នាំ២០០៧ ។

ក្រាហ្វិក ៤.១: គំនូសបំព្រួញនៃពាណិជ្ជកម្មជ័ទ្បូងឈើ



### របៀបអនុវត្តរបស់កសិករនៅភាគខាងលិច

កសិករភាគច្រើនលក់ដំឡូងឈើស្រស់ទៅឱ្យឈ្មួញ (តទៅនេះហៅថា ជម្រើសទី ១) ។ ក្នុងជម្រើសនេះ ឈ្មួញទូទាត់រាល់ចំណាយពាក់ព័ន្ធដូចជា ការប្រមូលផល និងការដឹកជញ្ជូន ។ ដោយបានថ្លៃជាមធ្យម ៣៣,៧៥ ដុល្លារអាមេរិកក្នុងមួយតោន និងទិន្នផលមធ្យម ២៤.០១តោនក្នុងមួយហិកតា ជម្រើសនៃការលក់បែបនេះផ្តល់ប្រាក់ចំណូលឱ្យកសិករបាន ៨១០,៣ដុល្លារអាមេរិកក្នុងមួយហិកតា ។

ជម្រើសលក់មួយបែបថ្មី គឺកសិករដឹកដំឡូងឈើស្រស់ទៅកាន់ឃ្លាំងរបស់ភ្នាក់ងាររោងចក្រ (តទៅនេះ ហៅថា ជម្រើសទី ២) ។ ក្នុងជម្រើសទី ២ នេះ ចំណាយប្រមូលផល និងចំណាយដឹកជញ្ជូន ជាបន្ទុករបស់កសិករ ។ ដោយបានថ្លៃមធ្យម ៤២,៤ដុល្លារក្នុងមួយតោន ហើយទិន្នផលមធ្យម ២៤,០១តោនក្នុងមួយហិកតា ការលក់តាមបែបនេះផ្តល់ចំណូលឱ្យកសិករបាន ១០២០,៤៣ដុល្លារអាមេរិកក្នុងមួយហិកតា ។ ដោយសារកង្វះពលកម្មក្នុងការប្រមូលផល និងកំណើនថ្លៃដឹកជញ្ជូន កសិករមិនសូវទុកចិត្តជ្រើសរើសយកការលក់បែបនេះឡើយ ។

ជម្រើសទី ៣ គឺកសិករលក់ដំឡូងឈើស្ងួតឱ្យឈ្មួញ ។ កសិករទូទាត់ថ្លៃប្រមូលផល ចំណែកឯចំណាយដឹកជញ្ជូនជាបន្ទុករបស់ឈ្មួញ ។ ដោយបានថ្លៃមធ្យម ៩០,៨៣ដុល្លារអាមេរិកក្នុងមួយតោន ទិន្នផលមធ្យម ២៤,០១តោនក្នុងមួយហិកតា និងបរិមាណដំឡូងឈើស្ងួតប្រហែល ៥៥ គ.ក្រ ក្នុងបរិមាណដំឡូងស្រស់ ១០០ គ.ក្រ កសិករទទួលប្រាក់ចំណូលបាន ១១៩៩,៣៩ ដុល្លារអាមេរិកក្នុងមួយហិកតា ។

**តារាង ៤.១: ចំណូលដុលពីការលក់ដំឡូងឈើនៅស្រុកកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧**

| | ជម្រើសទី ១ (ដំឡូងឈើស្រស់) | ជម្រើសទី ២ (ដំឡូងឈើស្រស់) | ជម្រើសទី ៣ (ដំឡូងឈើស្ងួត) |
|---|---|---|---|
| ថ្លៃ (ជាដុល្លារអាមេរិកក្នុងមួយតោន) | 33.75 | 42.4 | 90.83 |
| ទិន្នផលមធ្យម | 24.01 | 24.01 | 24.01 |
| ចំណូលដុលក្នុងមួយហិកតា | 810.3 | 1020.43 | 1199.39 |

*ប្រភព: ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យបានមកពីអង្កេតកសិករផលិតដំឡូងឈើ ឆ្នាំ២០០៨*

### របៀបអនុវត្តន៍របស់កសិករនៅភាគខាងកើត

ភាពខុសគ្នាសំខាន់មួយ រវាងរបៀបអនុវត្តន៍នៅភាគខាងលិច និងភាគខាងកើត គឺ ការលក់ដំឡូងឈើនៅភាគខាងកើត មិនផ្អែកលើទម្ងន់ជាក់ស្តែងនៃដំឡូងឈើឡើយ ប៉ុន្តែផ្អែកលើការម៉ៅទម្ងន់ក្នុងមួយហិកតា ។ ឈ្មួញចុះទៅដល់ចំការដើម្បីប៉ាន់ស្មានផលដំឡូង រួចទូទាត់តាមបែបម៉ៅដែលតទៅនេះហៅថា ជម្រើសទី ១ សំរាប់ភាគខាងកើត ។ ចំណាយប្រមូលផល និងចំណាយដឹកជញ្ជូន គឺជាបន្ទុករបស់ឈ្មួញ ។ កសិករនៅភាគខាងកើត ប្រមាណ ៣១% លក់ផលដំឡូងឈើរបស់ខ្លួនតាមរបៀបនេះ ។ ចំណូលមធ្យមពីការលក់បែបនេះ ដែលជាទឹកប្រាក់ទូទាត់ម៉ៅមានចំនួន ៦៦៧,៤៧ដុល្លារអាមេរិកក្នុងមួយហិកតា ។

មានកសិករភាគច្រើនណាស់នៅភាគខាងកើត ដែលសម្រេចចិត្តលក់ដំឡូងឈើស្រស់ឱ្យឈ្មួញ (ជម្រើស ទី ២) ។ ក្នុងករណីនេះ កសិកររ៉ាប់រងបន្ទុកចំណាយនៃការប្រមូលផល ចំណែកឯការដឹកជញ្ជូនជាបន្ទុករបស់ឈ្មួញ ។ កសិករប្រមាណ ៤៨% បានលក់ដំឡូងឈើរបស់ខ្លួនតាមជម្រើសនេះ ។ ដោយបានថ្លៃជាមធ្យម ៥៨.២៨ដុល្លារអាមេរិកក្នុងមួយតោន និងទិន្នផលមធ្យម ១៨,២៨តោនក្នុងមួយហិកតា ប្រាក់ចំណូលរបស់កសិករ គឺ ៧៧៤ដុល្លារក្នុងមួយហិកតា ។

ជម្រើសទី ៣ គឺការលក់ដំឡូងឈើស្ងួត ដែលក្នុងនេះកសិកររ៉ាប់រងបន្ទុកចំណាយលើការប្រមូលផល និងការដឹកជញ្ជូន ។ កសិករប្រមាណ ២០% បានលក់ដំឡូងឈើរបស់ខ្លួនតាមជម្រើសនេះ ។ ដោយបានថ្លៃជាមធ្យម ១៤៩.១ដុល្លារអាមេរិកក្នុងមួយតោន ទិន្នផលមធ្យម ១៣.២៨តោនក្នុងមួយហិកតា និងដំឡូងឈើស្ងួតប្រហែល ៥០ គ.ក្រ ក្នុងដំឡូងស្រស់ ១០០ គ.ក្រ កសិករទទួលចំណូលបាន ៩៩០.០៣ដុល្លារអាមេរិកក្នុងមួយហិកតា ។

កសិករស្ទើរតែទាំងអស់គ្មានកិច្ចសន្យាលក់ជាមុនជាមួយឈ្មួញ ឬជាមួយភ្នាក់ងាររោងចក្រឡើយ ហើយក្នុងករណីភាគច្រើនកសិករជាអ្នកទទួលយកថ្លៃតាមការកំណត់ ។ ឈ្មួញព្យាយាមទម្លាក់ថ្លៃនៅកន្លែងប្រមូលផលតាមដែលអាចធ្វើបាន ហើយស្ថានភាពជាអ្នកទទួលយកថ្លៃ ធ្វើឱ្យកសិករត្រូវចាញ់ប្រៀបគេក្នុងការចរចាថ្លៃ ។

នៅពេលសាកសួរពីភាពពេញចិត្តចំពោះកំរិតថ្លៃនៅពេលធ្វើអង្កេតនេះ កសិករបានបញ្ជាក់ទស្សនៈខុសៗគ្នា ។ ឧទាហរណ៍ កសិករប្រមាណ ៨៦% នៅភាគខាងលិចគិតថា ថ្លៃដែលពួកគេទទួលពីអ្នកប្រមូលទិញ/ឈ្មួញ ជាថ្លៃត្រឹមត្រូវ ចំណែកឯ ១៤% ទៀតយល់ថា ថ្លៃនេះទាបជាងថ្លៃទីផ្សារ ។ ក្នុងចំណោមកសិករនៅភាគខាងកើត ៤៣% គិតថា ពួកគេលក់បានតាមថ្លៃទីផ្សារ ចំណែកឯ ៣៨% អះអាងថា ឈ្មួញឱ្យថ្លៃពួកខ្លួនទាបជាងថ្លៃទីផ្សារ ។

**តារាង ៤.២: ចំណូលដុលពីការលក់ដំឡូងឈើនៅខេត្តកំពង់ចាម ឆ្នាំ២០០៧** (ជាដុល្លារអាមេរិក)

| | ជម្រើសទី ១ (រូបភាពម៉ៅ) | ជម្រើសទី ២ (ដំឡូងឈើស្រស់) | ជម្រើសទី ៣ (ដំឡូងឈើស្ងួត) |
|---|---|---|---|
| ថ្លៃ (ដុល្លារអាមេរិក/តោន) | - | 58.28 | 149.1 |
| ទិន្នផលមធ្យម | - | 13.28 | 13.28 |
| ចំណូលដុល/ហិកតា | 667.47 | 774 | 990.03 |

*ប្រភព: ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យបានមកពីអង្កេតកសិករផលិតដំឡូងឈើ ឆ្នាំ២០០៨*

## អ្នកប្រមូលទិញ

អ្នកប្រមូលទិញ ឬ "កូនដៃ" ឬ "ប្រម៉ោយ" តាមភាសាអ្នកស្រុកទីនោះ គឺជាភ្នាក់ងារទីផ្សារចំបងនៅក្នុងខ្សែរយៈទីផ្សារដំឡូងឈើ ។ ពួកគេជាភ្នាក់ងារឯករាជ្យរបស់ឈ្មួញ ហើយទទួលកម្រៃជើងសារផ្អែកលើចំនួនដំឡូងឈើដែលពួកគេបានទិញ ។ យោងតាមអង្កេតលើអ្នកប្រមូលទិញ ដូចជានៅស្រុកកំរៀងជាដើម អ្នកប្រមូលទិញម្នាក់ដែលតំណាងអោយឈ្មួញថៃ ក្នុងការទិញដំឡូងឈើពីកសិករ អាចទទួលបានកម្រៃជើងសារចំនួន ១.២៥ដុល្លារអាមេរិកក្នុងមួយតោន សំរាប់សេវារបស់ខ្លួន ។ អ្នកប្រមូលទិញមួយចំនួនធ្វើការឱ្យឈ្មួញក្នុងស្រុក ដែលក្រោយមកលក់ដំឡូងឈើទៅឱ្យឈ្មួញថៃ ដោយទទួលបានជាកម្រៃជើងសារ ឬអត្រាប្រាក់ចំណេញ ។ ក្នុងករណីនេះ អ្នកប្រមូលទិញទាំងនេះ ទទួលបានពី ០.៥០ ដល់ ០.៧៥ដុល្លារអាមេរិកក្នុងមួយតោន សំរាប់សេវារបស់ខ្លួន ។

## ឈ្មួញក្នុងស្រុក

នៅក្នុងតំបន់សិក្សាមានអ្នកមានជីវភាពធូរធារមួយចំនួនតូចប៉ុណ្ណោះ ដែលជាអ្នករកស៊ីនៅក្នុងអាជីវកម្មជួញដំឡូងឈើ ។ នេះគឺជាអាជីវកម្មមួយដែលផ្តល់ប្រាក់ចំណេញខ្ពស់ ប៉ុន្តែទាមទារឱ្យមានទុនច្រើន និងមានមូលដ្ឋានសម្ភារៈ (ឃ្លាំង) មានទំនាក់ទំនងល្អ និងទទួលទំនុកចិត្តពីសំណាក់កសិករ ។ ក្នុងកាលៈទេសៈខ្លះ ឈ្មួញក្នុងស្រុកដើរតួជាអ្នកប្រមូលទិញឱ្យឈ្មួញ

បរទេស ហើយបានទទួលកម្រៃជើងសារ ១,២៥ដុល្លារក្នុងមួយតោន ចំពោះសេវារបស់ខ្លួន ។ ជួនកាលឈ្មួញក្នុងស្រុកប្រកួតប្រជែងជាមួយឈ្មួញបរទេស ក្នុងការទិញដំឡូងឈើពីកសិករ ដើម្បីលក់ឱ្យឈ្មួញបរទេសក្នុងតម្លៃខ្ពស់ជាង ។

ឧទាហរណ៍ ឈ្មួញនៅភាគខាងលិចទិញដំឡូងឈើក្នុងតម្លៃជាមធ្យម ៣២,៥០ដុល្លារអាមេរិកក្នុងមួយតោន ហើយលក់ឱ្យឈ្មួញថៃជាមធ្យមក្នុងតម្លៃ ៤១,២៥ដុល្លារអាមេរិកក្នុងមួយតោន ។ ក្រោយពីបានចំណាយលើការប្រមូលផលប្រមាណជា ៥ដុល្លារអាមេរិកក្នុងមួយតោន ដោយអ្នកប្រមូលទិញ ឈ្មួញថៃរ៉ាប់រងលើថ្លៃដឹកជញ្ជូន ប្រាក់ចំណេញរបស់ឈ្មួញក្នុងស្រុកមានជាមធ្យម ៣,៧៥ដុល្លារអាមេរិកក្នុងមួយតោន ។ ចំពោះដំឡូងឈើស្ងួតវិញ ឈ្មួញទិញក្នុងថ្លៃជាមធ្យម ៩០ដុល្លារអាមេរិកក្នុងមួយតោន ហើយលក់ក្នុងថ្លៃជាមធ្យម ១០៥ដុល្លារអាមេរិកក្នុងមួយតោន ។ ដោយមានបន្ទុកចំណាយលើការប្រមូលផល និងការផ្ទុក ប្រហែល ៦,៥ដុល្លារអាមេរិកក្នុងមួយតោន ឈ្មួញក្នុងស្រុកចំណេញ ៨,៥ដុល្លារអាមេរិកក្នុងមួយតោន ។ តារាង ៤.៣ សង្ខេបជម្រើសនៃការជួញដូរ និងប្រាក់ចំណេញនៃវិធីជួញដូរនីមួយៗ ។ ការសម្រេចចិត្តរបស់ឈ្មួញអាស្រ័យលើកត្តាមួយចំនួន រាប់ទាំងការប្រាស្រ័យទាក់ទង និងទំនាក់ទំនងជាមួយឈ្មួញបរទេស វត្តមានសេវាពលកម្ម និងធនធានហិរញ្ញវត្ថុ ។

**តារាង ៤.៣៖ ប្រាក់ចំណេញរបស់ឈ្មួញក្នុងស្រុកនៅស្រុកកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧**
(ដុល្លារអាមេរិកក្នុងមួយតោន)

| | *ជម្រើសទី ១* | *ជម្រើសទី ២ (ដំឡូងឈើស្រស់)* | *ជម្រើសទី ៣ (ដំឡូងឈើស្ងួត)* |
|---|---|---|---|
| ថ្លៃនៅកន្លែងប្រមូលផល | 32.50 | 32.50 | 90 |
| ចំណាយលើការប្រមូលផល | 0 | 5 | 6.5 |
| ថ្លៃលក់ | 32.50 | 41.25 | 105 |
| **ប្រាក់ចំណេញ** | **1.25 (កម្រៃជើងសារ)** | **3.75** | **8.5** |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យបានមកពីអង្កេតកសិករផលិតដំឡូងឈើ ឆ្នាំ២០០៨*

### ៤.១.២ ចំណាយ និងចំណេញ

ចំណេញជាផលសងរវាងចំណូលពីការលក់ និងចំណាយ (រួមមាន ចំណាយផលិតកម្ម ចំណាយប្រមូលផល និងចំណាយដឹកជញ្ជូន) ។ ប្រាក់ចំណេញប្រែប្រួលទៅតាមរបៀបលក់ដំឡូងឈើ និងរបៀបគណនាមានបូកកត្តាផលិតកម្មគ្រួសារចូលក្នុងចំណាយផលិតកម្មដែរ ឬក៏អត់ ។ ដោយហេតុថា កសិករមានជម្រើសបី ក្នុងការលក់ផលដំឡូងឈើរបស់ខ្លួន ដូចមានបញ្ជាក់នៅខាងដើម ការវិភាគពីប្រាក់ចំណេញដូចតទៅនេះត្រូវបានញែកចេញជាបីករណី ហើយក្នុងករណីនីមួយៗមានចែកចេញជាពីរសេណារីយ៉ូ ។ ក្នុងសេណារីយ៉ូទី ១ ចំណាយផលិតកម្មមានគិតបញ្ចូលកត្តាផលិតកម្មគ្រួសារ ឯក្នុងសេណារីយ៉ូទី ២ ចំណាយផលិតកម្មគ្មានគិតបញ្ចូលកត្តាផលិតកម្មគ្រួសារទេ ។ តួលេខដែលបង្ហាញនៅខាងក្រោមផ្អែកលើលទ្ធផលអង្កេតនៅឆ្នាំ២០០៧ ។

### កម្រិតប្រាក់ចំណេញរបស់កសិករនៅភាគខាងលិច

តារាង ៤.២ បង្ហាញកម្រិតប្រាក់ចំណេញរបស់កសិករនៅស្រុកកំរៀង តាមជម្រើសទាំងបីនៃការលក់នៅឆ្នាំ២០០៧ ។ ជម្រើសទី ១ ដែលគេនិយមបំផុតនៅតំបន់នេះ ធ្វើឱ្យកសិករទទួលបានប្រាក់ចំណូល ៨១០,៣ដុល្លារអាមេរិកក្នុងមួយហិកតា ។ ក្នុងករណីដែលចំណាយប្រមូលផល និងចំណាយដឹកជញ្ជូន ជាបន្ទុករបស់ឈ្មួញ កម្រិតប្រាក់ចំណេញជាមធ្យមសំរាប់កសិករតាមជម្រើសនេះគឺ ៥១២,៦ដុល្លារអាមេរិកក្នុងមួយហិកតា ប្រសិនបើគេមិនបូកបញ្ចូលកត្តាផលិតកម្ម និងពលកម្មគ្រួសារនៅក្នុងការគណនាចំណាយទេ (សេណារីយ៉ូទី ២) រឺ ៣៤៥,៥ដុល្លារអាមេរិកក្នុងមួយហិកតា ក្នុងករណីគេបូកបញ្ចូលកត្តាផលិតកម្មគ្រួសារនៅក្នុងចំណាយផលិតកម្ម ។

ចំពោះសេណារីយ៉ូទី ២ វិញ ចំណូលពីជម្រើសទី ២ និងទី ៣ មានទំហំធំជាង ប៉ុន្តែត្រូវកាត់ចេញអស់មួយចំណែកវិញនូវចំណាយលើការប្រមូលផល (១៦០ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ២ និង ៣៧២ដុល្លារអាមេរិកសំរាប់ជម្រើសទី ៣) ហើយនិង ចំណាយដឹកជញ្ជូន (៤១,៥៣ដុល្លារអាមេរិក) ។ ប្រសិនបើគ្មានបូកបញ្ចូលកត្តាផលិតកម្ម និងពលកម្មគ្រួសារ នៅក្នុងចំណាយផលិតកម្មទេនោះ (សេណារីយ៉ូទី ២) កសិករបានចំណេញរហូតដល់ ៥២៩,៦៩ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ៣ និង ៥២១,២ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ២ ។ តារាង ៤.៤ ក៏បង្ហាញដែរថា កម្រិតប្រាក់ចំណេញប្រែប្រួលខុសគ្នាតិចតួចទេក្នុងចំណោមជម្រើសទាំងបី ដូច្នេះហើយបានជាកសិករមិនបោះបង់ចោលរបៀបរបបបច្ចុប្បន្ននៃការលក់ដំឡូង ពីព្រោះវាធ្វើឱ្យពួកគេចំណេញពេលវេលា ។

លទ្ធផលរកឃើញបញ្ជាក់គាំទ្រនូវព័ត៌មានទទួលបាន តាមរយៈកិច្ចសម្ភាសន៍ស៊ីជម្រៅបែបគុណវិស័យជាមួយកសិករដែលថា កសិករភាគច្រើននិយមអនុវត្តជម្រើសទី ១ ដោយសារជម្រើសពីរទៀត តម្រូវឱ្យពួកគេធ្វើសកម្មភាពជាច្រើនទៀត ដូចជា ការប្រមូលផល ការចិតមើម ការហាល និងការប្រមូលចំណិតដំឡូងឈើ ។ កម្រិតប្រាក់ចំណេញខុសគ្នាមិនច្រើនគ្រប់គ្រាន់ល្មមឱ្យពួកគេសាកល្បងអនុវត្តនូវជម្រើសផ្សេងទៀតឡើយ ។ ប្រសិនបើគេបូកបញ្ចូលកត្តាផលិតកម្មគ្រួសារនៅក្នុងចំណាយផលិតកម្មផង (សេណារីយ៉ូទី ១) ប្រាក់ចំណេញធ្លាក់ចុះមកត្រឹម ៣៤៥,៥ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ១, ៣៥៤,១ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ២ និង ៣៦២,៥៩ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ៣ ។ ដូចក្នុងសេណារីយ៉ូទី ២ ដែរ លទ្ធផលបង្ហាញថា ភាពខុសគ្នានៃកម្រិតប្រាក់ចំណេញរវាងជម្រើសទាំងនេះមានតិចតួចណាស់ ។

**តារាង ៤.៤: កម្រិតប្រាក់ចំណេញពីដំណាំដំឡូងឈើនៅកំរៀង ខេត្តបាត់ដំបង ឆ្នាំ២០០៧** (គិតជាដុល្លារអាមេរិក)

| | ជម្រើសទី ១ | | ជម្រើសទី ២ | | ជម្រើសទី ៣ | |
|---|---|---|---|---|---|---|
| | សេណារីយ៉ូទី ១ | សេណារីយ៉ូទី ២ | សេណារីយ៉ូទី ១ | សេណារីយ៉ូទី ២ | សេណារីយ៉ូទី ១ | សេណារីយ៉ូទី ២ |
| **ក. ចំណូលដុល** | 810.3 | 810.3 | 1020.43 | 1020.43 | 1199.39 | 1199.39 |
| **ខ. ចំណាយសរុប** | 464.8 | 297.7 | 666.33 | 499.23 | 836.8 | 669.7 |
| - ចំណាយផលិតកម្ម | 464.8 | 297.7 | 464.8 | 297.7 | 464.8 | 297.7 |
| - ចំណាយប្រមូលផល | 0 | 0 | 160 | 160 | 372 | 372 |
| - ចំណាយដឹកជញ្ជូន (ប្រសិនបើមាន) | 0 | 0 | 41.53 | 41.53 | 0 | 0 |
| **គ. កម្រិតចំណេញ** | **345.5** | **512.6** | **354.1** | **521.2** | **362.59** | **529.69** |

*ប្រភព: ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យបានមកពីអង្កេតកសិករដាំដំឡូងឈើ ឆ្នាំ២០០៨*

### កម្រិតប្រាក់ចំណេញរបស់កសិករនៅភាគខាងកើត

ដូចនៅភាគខាងលិចដែរ ការវិភាគប្រាក់ចំណេញនៅស្រុកមេមត់នៅឆ្នាំ២០០៧ ចែកចេញជាជម្រើសចំនួនបី និងសេណារីយ៉ូចំនួនពីរ ។ សេណារីយ៉ូមានលក្ខណៈដូចគ្នាបេះបិតគឺ សំរាប់សេណារីយ៉ូទី ១ ចំណាយផលិតកម្មមានបូកបញ្ចូលនូវកត្តាផលិតកម្មគ្រួសារ ហើយសំរាប់សេណារីយ៉ូទី ២ មានបូកបញ្ចូលតែកត្តាផលិតកម្មដែលទិញគេប៉ុណ្ណោះ ។ ដូចបានបញ្ជាក់នៅក្នុងផ្នែកមុននេះ ចំណូលរបស់កសិករគឺ ៦៦៧,៤៧ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ១, ៧៧៤ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ២ និង ៩៩០,០៣ដុល្លារអាមេរិកក្នុងមួយហិកតាសម្រាប់ជម្រើសទី ៣ ។

តារាង ៤.៥ បង្ហាញថា ប្រសិនបើកត្តាផលិតកម្ម និងពលកម្មគ្រួសារ មិនបូកបញ្ចូលក្នុងការគណនាចំណាយទេ (សេណារីយ៉ូទី ២) កម្រិតប្រាក់ចំណេញឡើងដល់ ៥៤២,៣៧ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ១, ៦២០,៤៨ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ២ និង ៧៧៩,៤៧ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ៣ ។ លទ្ធផលទាំងនេះបង្ហាញថា ជម្រើសទី ៣ ផ្តល់ប្រាក់ចំណេញខ្ពស់បំផុត និងច្រើនជាងជម្រើសដទៃគួរឱ្យកត់សំគាល់ ។ ទោះយ៉ាងនេះក្តី ពុំមែនកសិករទាំងអស់គ្នាសុទ្ធតែមានលទ្ធភាពជ្រើសយកជម្រើសនេះបានឡើយ ។ គេសង្កេតឃើញថាមានតែកសិករធូរធារមួយក្រុមតូចដែលមានកូនរថយន្តសំរាប់ដឹកជញ្ជូននោះទេ ដែលទទួលបានកម្រិតប្រាក់ចំណេញច្រើនពីការលក់ដំឡូងឈើ ហើយកសិករប្រភេទនេះ ក៏ដើរតួជាឈ្មួញកណ្តាលផងដែររវាងកសិករ និងឈ្មួញបរទេស ។

**តារាង ៤.៥: កម្រិតប្រាក់ចំណេញពីដំណាំដំឡូងឈើនៅមេមត់ ខេត្តកំពង់ចាម ឆ្នាំ២០០៧**
**(គិតជាដុល្លារអាមេរិក)**

| | ជម្រើសទី ១ | | ជម្រើសទី ២ | | ជម្រើសទី ៣ | |
|---|---|---|---|---|---|---|
| | សេណារីយ៉ូទី ១ | សេណារីយ៉ូទី ២ | សេណារីយ៉ូទី ១ | សេណារីយ៉ូទី ២ | សេណារីយ៉ូទី ១ | សេណារីយ៉ូទី ២ |
| ក.ចំណូលដុល | 666.47 | 666.47 | 774 | 774 | 990.03 | 990.03 |
| ខ. ចំណាយសរុប | 329.1 | 124.1 | 374.26 | 153.52 | 439.17 | 210.56 |
| - ចំណាយផលិតកម្ម | 329.1 | 124.1 | 329.1 | 124.1 | 329.1 | 124.1 |
| - ចំណាយប្រមូលផល | 0 | 0 | 45.16 | 29.42 | 67.74 | 44.13 |
| - ចំណាយដឹកជញ្ជូន (ប្រសិនបើមាន) | 0 | 0 | 0 | 0 | 42.33 | 42.33 |
| **គ. ចំណេញ** | **337.37** | **542.37** | **399.74** | **620.48** | **550.86** | **779.47** |

*ប្រភព: ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យបានមកពីអង្កេតកសិករផលិតដំឡូងឈើ ឆ្នាំ២០០៨*

ប្រសិនបើគេគិតបញ្ចូលកត្តាផលិតកម្មគ្រួសារទៅក្នុងចំណាយផលិតកម្មសរុប (សេណារីយ៉ូទី ១) ប្រាក់ចំណេញធ្លាក់ចុះដល់ ៣៣៧,៣៧ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ១, ៣៩៩,៧៤ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ២ និង ៥៥០,៨៦ដុល្លារអាមេរិកក្នុងមួយហិកតាសំរាប់ជម្រើសទី ៣ ។ ដូចនៅក្នុងសេណារីយ៉ូទី ២ ដែរ កម្រិតប្រាក់ចំណេញរវាងជម្រើសទី ១ និងជម្រើសទី ២ ខុសគ្នាតែតិចតួច ប៉ុន្តែសំរាប់ជម្រើសទី ៣ វាខុសគ្នាច្រើនពីជម្រើសឯទៀត ។

### ៤.១.៣. បញ្ហាប្រឈម និងឱកាសល្អ

#### បញ្ហាប្រឈម

ឧបសគ្គមានច្រើនសណ្ឋានដែលប្រឈមនឹងតួអង្គសំខាន់ៗនៅក្នុងខ្សែចង្វាក់ទីផ្សារដំឡូងឈើ ។ ទីមួយ គឺកង្វះព័ត៌មានទីផ្សារ ជាពិសេសក្នុងចំណោមកសិករ ។ ថ្លៃដំឡូងឈើបន្តកើនឡើងជាបន្តបន្ទាប់ ហើយឈ្មួញបរទេសបានដឹងច្បាស់ ព្រោះពួកគេភាគច្រើនជាអ្នកកំណត់ថ្លៃ ។ ដោយសារកសិករមិនសូវដឹងពីកម្រិតថ្លៃថ្មីៗបំផុត ដូច្នេះនៅកន្លែងប្រមូលផលតាមធម្មតាគេបង្អាប់ថ្លៃឱ្យទាបជាខ្លាំងជាងថ្លៃទីផ្សារបច្ចុប្បន្ន ។

ឧបសគ្គទីពីរ នៅក្នុងលំហូរពាណិជ្ជកម្ម គឺហេដ្ឋារចនាសម្ព័ន្ធរូបវន្តអន់ខ្សោយ ។ ផ្លូវថ្នល់ដែលតភ្ជាប់កន្លែងផលិតដំឡូងឈើធំៗទៅកាន់តំបន់ទីក្រុងសំខាន់ៗ និងទៅកាន់កន្លែងត្រួតពិនិត្យ មានស្ថានភាពអន់ណាស់ ។ ប្រការនេះធ្វើឱ្យចំណាយដឹកជញ្ជូន និងចំណាយប្រតិបត្តិការ មានកម្រិតខ្ពស់នៅក្នុងខ្សែរយៈទីផ្សារ ។ ស្ថានភាពផ្លូវថ្នល់មិនល្អ ក៏បង្កឧបសគ្គដល់រោងចក្រកែច្នៃនៅតាមតំបន់ទីក្រុងដែរ ក្នុងការប្រកួតប្រជែងឱ្យបានល្អជាមួយឈ្មួញបរទេស លើការទិញដំឡូងឈើពីកសិករ ពីព្រោះបន្ទុកចំណាយខ្ពស់ក្នុងការចូលទៅដល់ចំការដំឡូង ធ្វើឱ្យពួកគេត្រូវចាញ់ប្រៀប ។ ដូច្នេះកសិករមានជម្រើសតិចតួចលើឈ្មួញដែលខ្លួនត្រូវលក់ផលិតផលឱ្យ និងមានកម្លាំងតិចតួចក្នុងការកំណត់ថ្លៃ ។

ទីបី តម្លៃបន្ថែមមានតិចតួចណាស់នៅក្នុងខ្សែរយៈកំណត់តម្លៃដំឡូងឈើ ។ ផលដំឡូងឈើភាគច្រើននៅក្នុងតំបន់សិក្សា គេនាំចេញឆ្លងកាត់ព្រំដែនទៅកាន់ប្រទេសថៃ និងវៀតណាម ដែលនៅទីនោះមានការកែច្នៃបន្តសំរាប់នាំចេញទៅប្រទេសទីបី ។ រោងចក្រកែច្នៃឃើញមានតិចតួចនៅតាមទីក្រុងសំខាន់ៗ និងនៅតាមកន្លែងផលិត ហើយកត្តាផ្សេងៗក្នុងការកែច្នៃ ដូចជា វត្ថុធាតុដើម ប្រេងឥន្ធនៈ និងអគ្គិសនី មានថ្លៃខ្ពស់ណាស់ ។ ខុសពីរោងចក្រកាត់ដេរសម្លៀកបំពាក់ ពាណិជ្ជកម្ម និងការកែច្នៃដំឡូងឈើទទួលបានការគាំទ្រផ្នែកពាណិជ្ជកម្មតិចតួចណាស់ ។ ក្នុងពេលពុំទាន់មានមូលដ្ឋានសម្ភារៈបច្ចេកទេសដ៏ចាំបាច់ ដំណាំដំឡូងឈើខ្លួនឯងផ្ទាល់មិនអាចផ្តល់តម្លៃបន្ថែមបានច្រើនឡើយ ។

បញ្ហាទីបួន ដែលកើតចេញពីលំហូរពាណិជ្ជកម្មដំឡូងឈើ វាជាប់ទាក់ទងនឹងព្រំដែន ។ ឈ្មួញតែងត្អូញត្អែរពីការយកប្រាក់កម្រៃឆ្លងដែនខ្ពស់ ដូចជា ក្នុងករណីស្រុកកំរៀង ឈ្មួញត្រូវបង់ ១០០-១៥០ដុល្លារអាមេរិក ទៅឱ្យមន្ត្រីព្រំដែនកម្ពុជា និងថៃ ដើម្បីដឹកដំឡូងឈើឆ្លងកាត់ព្រំដែន ។ ប្រាក់កម្រៃនេះប៉ះពាល់ដោយផ្ទាល់ដល់កម្រិតប្រាក់ចំណេញរបស់ឈ្មួញ និងប៉ះពាល់ដោយប្រយោលដល់កម្រិតប្រាក់ចំណេញរបស់កសិករ ។ បញ្ហាពាក់ព័ន្ធមួយទៀត គឺការបិទព្រំដែនមិនអាចស្មានដឹងដែលកើតមានម្តងម្កាលនៅព្រំដែនរវាងកម្ពុជា និងថៃ ។ សភាពការណ៍កាន់តែអាក្រក់ថែមទៀត ប្រសិនបើការបិទព្រំដែនបណ្តោះអាសន្នកើតឡើងក្នុងអំឡុងពេលប្រមូលផល ពីព្រោះមិនអាចដឹកដំឡូងឆ្លងកាត់ព្រំដែនបាន ដូច្នេះហើយកម្រិតថ្លៃនៅកន្លែងប្រមូលផលក៏ធ្លាក់ចុះ ។ កិច្ចសម្ភាសន៍ស៊ីជម្រៅជាមួយប្រធានភូមិបង្ហាញថា ពួកកសិករ ជាពិសេសអ្នកដែលត្រូវការប្រាក់ជាបន្ទាន់ពីការប្រមូលផលដើម្បីសងបំណុលគេ ត្រូវរងផលប៉ះពាល់អវិជ្ជមានពីការបិទព្រំដែនបណ្តោះអាសន្ននេះ ។

#### ឱកាសល្អ

ឱកាសល្អថ្មីៗមានច្រើនសណ្ឋាននៅក្នុងខ្សែរយៈទីផ្សារដំឡូងឈើ និងពាណិជ្ជកម្មដំឡូងឈើ ។ ទីមួយគឺ ការកើនឡើងជាទៀងទាត់នូវថ្លៃដំឡូងឈើនៅលើទីផ្សារអន្តរជាតិ ។ ថ្លៃដំឡូងឈើបានកើនឡើងយ៉ាងច្រើនក្នុងរយៈពេល ៧ឆ្នាំចុងក្រោយ ដោយមានអត្រាកំណើនជាមធ្យម ១២% ហើយកំណើនយ៉ាងលឿនបែបនេះ គឺជាលទ្ធផលនៃកំណើនតម្រូវការដំឡូងឈើ ។ ឧទាហរណ៍ ថ្លៃដំឡូងឈើ (ចំណិតឈូសស្ងួត) F.O.B បាងកក គឺ ១១៣,២៥ដុល្លារអាមេរិកក្នុងមួយតោននៅឆ្នាំ២០០៧ ធៀបនឹង ៧៨,០៤ដុល្លារអាមេរិកនៅឆ្នាំ២០០៤ និង ៥៥ដុល្លារអាមេរិកនៅឆ្នាំ២០០០ ។ ថ្លៃម្សៅដំឡូងឈើ F.O.B បាងកក

គឺ ២៥០,៥ដុល្លារអាមេរិកក្នុងមួយតោន នៅឆ្នាំ២០០៧ ធៀបនឹង ១៥៧,៤២ដុល្លារអាមេរិកក្នុងមួយតោន នៅឆ្នាំ២០០០[៨] ។ យោងតាមកំណើនតម្រូវការនៅលើពិភពលោក និងនៅក្នុងតំបន់ ថ្លៃដំឡូងឈើទំនងជាបន្តកើនឡើងទៀត ។

ឱកាសល្អផុសថ្មីទីពីរ សំរាប់ពាណិជ្ជកម្មដំឡូងឈើ គឺសក្តានុពលខ្ពស់សំរាប់ការនាំចេញ និងពិពិធកម្មទីផ្សារ ។ ដំឡូងឈើស្ថិតក្នុងវិស័យនាំចេញជាអាទិភាពទាំង ១៩មុខ ដែលបានកំណត់ដោយរដ្ឋាភិបាល សំរាប់ដាក់បញ្ចូលទៅក្នុងឯកសារ DTIS ឆ្នាំ២០០៧ ។ ទោះជាក្នុងពេលបច្ចុប្បន្ន ការនាំចេញដំឡូងឈើនៅមិនទាន់មានចំនួនច្រើនក្តី ក៏ដំឡូងឈើត្រូវបានចាត់ទុកថាជាផលិតផលដ៏សំខាន់ មានសក្តានុពលនាំចេញយ៉ាងខ្ពស់ ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារពិភពលោក និងសមត្ថភាពល្អរបស់កម្ពុជាក្នុងការផ្គត់ផ្គង់ដំឡូងឈើ ។ ទាក់ទិននឹងលទ្ធភាពចូលទីផ្សារ ការនាំចេញដំឡូងឈើពីប្រទេសកម្ពុជាបានទទួលលក្ខខណ្ឌអនុគ្រោះពន្ធពីប្រទេសជាច្រើន ដូចជា សមាជិកអាស៊ាន សហភាពអឺរ៉ុប និងប្រទេសចិន តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ឬកម្មវិធីស្តីពី ប្រព័ន្ធអនុគ្រោះទូទៅ (GSP) សំរាប់ប្រទេសលូតលាស់តិចជាងគេ (LDCs) ។

ឱកាសល្អទីបី គឺការពង្រីកតម្លៃបន្ថែមនៅក្នុងខ្សែរយៈកំណត់តម្លៃដំឡូងឈើ ។ ដោយសារគេអាចប្រើដំឡូងឈើបានច្រើនមុខច្រើនបែប និងអាចកែច្នៃជាផលិតផលផ្សេងៗ ឧស្សាហកម្មដំឡូងឈើអាចជាកន្លែងទាក់ទាញវិនិយោគទៅក្នុងកសិ-ឧស្សាហកម្ម ដូចជា ការកែច្នៃស្បៀងអាហារ ថ្នាំពេទ្យ ជីវ-ឥន្ធនៈ ចំណីសត្វ និងស្រា (MoC, 2007) ។ ការលូតលាស់កសិ-ឧស្សាហកម្មទាំងនេះ នឹងជះឥទ្ធិពលយ៉ាងច្រើនដល់ផលិតកម្មដំឡូងឈើ និងការចិញ្ចឹមជីវិតរបស់កសិករ ។

## ៤.២. ពាណិជ្ជកម្មកៅស៊ូ

### ៤.២.១. ខ្សែរយៈទីផ្សារ

**ការគូសផែនទីគន្លងផ្លូវពីចំការទៅដល់កន្លែងនាំចេញ**

ពីចំការទៅកន្លែងនាំចេញ គេឃើញមានតួអង្គសំខាន់ជាច្រើន ដូចមានបង្ហាញក្នុង ក្រាហ្វិក ៤.២ ។ កសិករដាំដំណាំកៅស៊ូដែលស្ថិតនៅក្បែររោងចក្រ លក់ទឹកជ័ររបស់ខ្លួនឱ្យរោងចក្រ ចំណែកអ្នកមានចំការនៅឆ្ងាយពីផ្លូវធំ និងឆ្ងាយពីរោងចក្រត្រូវបង្កកទឹកជ័រមុនពេលលក់ ។ ដើម្បីបង្កកទឹកជ័រ កសិករគ្រាន់តែចាក់ទឹកជ័រទៅក្នុងរណ្តៅមួយនៅលើដី ហើយទុកចោល២-៣ថ្ងៃ មុនពេលដែលអ្នកទិញមកប្រមូលយក ។

ក្រាហ្វិក ៤.២: គំនូសបំព្រួញផលិតផលកៅស៊ូនៅកម្ពុជា




[៨] ថ្លៃទំនិញអន្តរជាតិរបស់អង្គការ FAO: http://www.fao.org/es/esc/prices/PricesServlet.jsp?lang=en

នាបច្ចុប្បន្នកសិករមានជម្រើសច្រើនជាងមុន លើអ្នកដែលខ្លួនចង់លក់ផលិតផលឱ្យ ។ នេះជាលទ្ធផលនៃសេដ្ឋកិច្ចទីផ្សារសេរី ដែលអនុញ្ញាតឱ្យមានឈ្មួញ និងសហគ្រាសច្រើន ចូលមកទាក់ទង និងទិញ ផលិតផលនៅកន្លែងណាមួយ ។ យោងតាមអង្កេត កសិករភាគច្រើន (៦៣%) លក់ផលិតផលរបស់ខ្លួនទៅឱ្យអ្នកលក់ដុំ (អ្នកដែលមានបណ្តាញក្នុងការទិញទឹកជ័រដល់ចំការ ហើយទៅលក់ឱ្យរោងចក្រ) ។ កសិករ ៣០% (ភាគច្រើនជាអ្នកមានចំការនៅក្បែររោងចក្រ) លក់ផលិតផលរបស់ខ្លួនដោយផ្ទាល់ទៅឱ្យរោងចក្រ ។ កសិករដំណាំកៅស៊ូ ៧% ទៀត លក់ផលិតផលរបស់ខ្លួនទៅឱ្យអ្នកប្រមូលទិញ ។

**តារាង ៤.៦: ទីផ្សារកៅស៊ូសំរាប់កសិករ**

| *ប្រភេទបុគ្គលដែលកសិករលក់ផលិតផលឱ្យ* | *ភាគរយ* |
|---|---|
| អ្នកកែច្នៃ ឬរោងចក្រ | 30 |
| អ្នកប្រមូលទិញ | 7 |
| អ្នកលក់ដុំ (ទិញសំរាប់កែច្នៃ រួចលក់) | 63 |

*ប្រភព: អង្កេតកសិករដំណាំកៅស៊ូឆ្នាំ២០០៧ របស់ វិបសអ*

អ្នកលក់ដុំ ទិញទឹកជ័រពីកសិករម្ចាស់ចំការតូចៗ សំរាប់លក់ទៅឱ្យរោងចក្រ ឬដឹកជញ្ជូនទៅរោងចក្រ ដើម្បីកែច្នៃ ហើយនាំចេញ ។ ចំពោះអ្នកប្រមូលទិញតូចតាចវិញ ពួកគេទិញទឹកជ័រពីកសិករ ហើយលក់ទៅឱ្យអ្នកលក់ដុំ ឬលក់ឱ្យរោងចក្រនៅក្នុងតំបន់របស់ពួកគេ ។ មានអ្នកប្រមូលទិញមួយចំនួនដែរ ដែលទិញកៅស៊ូដើម្បីយកទៅលក់នៅប្រទេសវៀតណាម ។ សកម្មភាពនេះជាអំពើខុសច្បាប់ ប៉ុន្តែឃើញមានអនុវត្តជាក់ស្តែង ។ ពួកគេដឹកកៅស៊ូតាមម៉ូតូ ដោយអាចដឹកបានរហូតដល់ ៣០០គ.ក្រ ក្នុងម៉ូតូនីមួយៗ ។ អ្នកលក់ដុំម្នាក់អាចទិញចូលបានពី ១០ ទៅ ២០តោនក្នុងមួយថ្ងៃ ប៉ុន្តែបរិមាណនេះអាចចុះថយមកត្រឹមប្រហែល ១០តោនក្នុងមួយថ្ងៃ នៅពេលមានអ្នកប្រមូលទិញតូចតាច ធ្វើសកម្មភាពប្រមូលទិញមមាញឹក ។

កម្ពុជាបាននាំចេញអង្ករ និងផលិតផលកសិកម្មដទៃទៀត ទៅកាន់ប្រទេសថៃ និងប្រទេសវៀតណាម ដោយគ្មានការកត់ត្រាអ្វីឡើយ ហើយក៏ពុំមានទិន្នន័យផ្លូវការអ្វីដែរអំពីបរិមាណនាំចេញមិនបានកត់ត្រាទាំងនេះ[៩] ។ សំរាប់ផលិតផលកៅស៊ូក៏ដូចគ្នាដែរ ។ នៅឆ្នាំ២០០៤ កម្ពុជាបានកត់ត្រាថា មានការនាំចេញកៅស៊ូចំនួន ៣៩លានដុល្លារ ចំណែកឯការនាំចេញកៅស៊ូមិនបានកត់ត្រាមានប្រហែល ៧៦លានដុល្លារ ។ ប៉ុន្តែគំលាតរវាងបរិមាណបានកត់ត្រា និងមិនបានកត់ត្រា បានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗ ប៉ុន្តែក៏នៅតែមានតួលេខធំនៅឡើយ ។ តាមការសិក្សានេះ តួលេខប៉ាន់ស្មាននៃបរិមាណមិនបានកត់ត្រាគឺស្មើគ្នានឹងបរិមាណបានកត់ត្រា ។

### ៤.២.២. ការកែច្នៃ

កន្លងមកកៅស៊ូផលិតបាននៅកម្ពុជា គឺសំរាប់តែនាំចេញប៉ុណ្ណោះ ដោយសារកង្វះសមត្ថភាព និងកង្វះការវិនិយោគលើការកែច្នៃកៅស៊ូធម្មជាតិទៅជាផលិតផលប្រើប្រាស់ ដូចជាសំបកកង់រថយន្តជាដើម ។ មានតែកៅស៊ូពាក់កណ្តាលកែច្នៃប៉ុណ្ណោះ (គឺកៅស៊ូស្ងួត មិនមែនទឹកជ័រកៅស៊ូទេ) ដែលត្រូវបានអនុញ្ញាតឱ្យនាំចេញ ។ សហគ្រាសរដ្ឋទាំងអស់មានរោងចក្រកែច្នៃកៅស៊ូ ។ រដ្ឋាភិបាលបានចេញការហាមឃាត់លើការនាំចេញកៅស៊ូមិនបានកែច្នៃ ហើយការហាមឃាត់នេះធ្វើឱ្យកសិករកៅស៊ូគ្រួសារមានជម្រើសតិចតួច ត្រឹមតែលក់ទឹកជ័រដែលប្រមូលបានទៅឱ្យសហគ្រាសរដ្ឋ និងឯកជន ដើម្បីកែច្នៃសំរាប់

[៩] សៀវភៅមគ្គុទេសក៍ពាណិជ្ជកម្មសំរាប់កម្ពុជា ឆ្នាំ២០០៦ អាចរកបាននៅលើគេហទំព័រ http://cambodia.usembassy.gov/ ។

នាំចេញ ។ ក្រៅពីការកែច្នៃជ័រកៅស៊ូ ក៏មានការកែច្នៃដើមកៅស៊ូឱ្យទៅជាសង្ហារឹមដែរ ប៉ុន្តែដើមកៅស៊ូភាគច្រើនគឺ សំរាប់នាំចេញទៅប្រទេសវៀតណាម ដែលនៅទីនោះគេកែច្នៃវាទៅជាសង្ហារឹម ។

កម្ពុជាផលិត និងនាំចេញភាគច្រើននូវកៅស៊ូប្រភេទ TSR5 និង TSR5L ដែលតំណាងឱ្យប្រហែល ៨៩% នៃបរិមាណនាំចេញសរុប[១០] ។ ទោះជាយ៉ាងនេះក្តី កៅស៊ូទាំងពីរប្រភេទនេះ មានចំណែកត្រឹមតែប្រហែល ៥% នៃតម្រូវការសរុបក្នុងពិភពលោកប៉ុណ្ណោះ ។ ប្រសិនបើកម្ពុជាចង់បង្កើនចំណែកទីផ្សារនៅពេលអនាគត កម្ពុជាគួរពិចារណាពីការផលិតប្រភេទផ្សេង (ដូចជា TSR10 និង TSR20 ជាដើម) ដែលពិភពលោកមានតម្រូវការខ្ពស់សំរាប់ផលិតសំបកកង់រថយន្ត ។

### ៤.២.៣. ចំណាយ និងចំណេញ

#### ថ្លៃនៅកន្លែងប្រមូលផល

យោងតាមអង្កេតលើកសិករ កសិករដំណាំកៅស៊ូអាចលក់ទឹកជ័ររបស់ខ្លួនបានប្រហែល ១៧៥០ដុល្លារក្នុងមួយតោន នៃចំណុះជាកៅស៊ូស្ងួត (dry rubber content: DRC) នៅក្នុងទឹកជ័រនោះ នៅឯកន្លែងប្រមូលផល ។

#### ឈ្មួញកណ្តាល

ឈ្មួញកណ្តាល ឬអ្នកលក់ដុំ ទិញទឹកជ័រ និងដឹកជញ្ជូនទៅស្តុកទុក ។ ការប្រមូលទឹកជ័រពីចំការ ការដឹកជញ្ជូន ការសម្ងួត និងការស្តុក អស់ចំណាយប្រហែល ១២៥ដុល្លារក្នុងមួយតោននៃជ័រស្ងួត ។

#### ការកែច្នៃ

ការកែច្នៃកៅស៊ូទៅជាកៅស៊ូស្ងួត (កៅស៊ូដុំ) អស់ចំណាយប្រហែល ១០០ដុល្លារអាមេរិកក្នុងមួយតោននៃកៅស៊ូស្ងួត ។ កាលពីប៉ុន្មានឆ្នាំមុន ចំណាយកែច្នៃមានកម្រិតខ្ពស់ដល់ ១២៥ដុល្លារអាមេរិកក្នុងមួយតោន ។ ការថយចុះចំណាយកែច្នៃនេះផុសចេញពីការប្រកួតប្រជែងរវាងរោងចក្រ និងការផ្គត់ផ្គង់អគ្គិសនីនាំចូលពីវៀតណាមដែលមានតម្លៃថោក ។

#### ការនាំចេញ

ជាផ្លូវការមានតែកៅស៊ូក្រែបប៉ុណ្ណោះ (កៅស៊ូស្ងួតក្រោយពីពាក់កណ្តាលកែច្នៃ) ដែលត្រូវបានអនុញ្ញាតឱ្យនាំចេញ ។ ប៉ុន្តែការនាំចេញកៅស៊ូដុំនៅដោយខុសច្បាប់ទៅវៀតណាមនៅតែឃើញមាន ហើយគេប៉ាន់ស្មានថា មានការលក់ចេញកៅស៊ូដុំប្រហែល ៥០០គ.ក្រ ជារៀងរាល់ថ្ងៃទៅឱ្យវៀតណាមនៅរដូវប្រមូលផល ។

នៅឆ្នាំ២០០៥ ថ្លៃលក់គឺ ១៣៩១ដុល្លារក្នុងមួយតោន ធៀបនឹងត្រឹម ១១៧៥ដុល្លារក្នុងមួយតោន កាលពីឆ្នាំមុន ហើយវាបានកើនឡើងរហូតដល់ ២៣៣០ដុល្លារក្នុងមួយតោន នៅពេលធ្វើអង្កេត ។ ការនាំចេញកៅស៊ូត្រូវបង់ពន្ធ ១០% ។ តាមធម្មតាអ្នកនាំចេញប្រើរថយន្តដឹកជញ្ជូនធំៗ ដើម្បីដឹកកៅស៊ូក្រែបពីរោងចក្រទៅប្រទេសវៀតណាម ។ ចំណាយដឹកជញ្ជូននៅលើផ្លូវកៅស៊ូអស់ប្រហែល ៣-៤ដុល្លារក្នុងមួយតោន ក្នុងចម្ងាយផ្លូវ ១០គីឡូម៉ែត្រ ។

---

១០ តួលេខនេះ គឺសំរាប់ឆ្នាំ២០០៥ ដកស្រង់ចេញពី EIC (2007) ។

### ៤.៧.៤. ឧបសគ្គ និងឱកាសល្អ

តម្រូវការកៅស៊ូមានកម្រិតខ្ពស់នៅឆ្នាំ២០០៧ និង ២០០៨ ។ កិច្ចសម្ភាសន៍ជាមួយឈ្មួញបានឱ្យដឹងថា តម្រូវការខ្ពស់ផុសចេញពីតម្រូវការកៅស៊ូច្រើននៅប្រទេសចិន ។ កៅស៊ូពីក្រុមហ៊ុនធំៗនៅកម្ពុជា ត្រូវបាននាំចេញទៅប្រទេសចិន ឬប្រទេសម៉ាឡេស៊ី ដោយឆ្លងកាត់តាមប្រទេសវៀតណាម ។ ចំពោះកៅស៊ូនៅរោងចក្រតូចៗវិញ ក្រុមហ៊ុនវៀតណាមបានប្រមូលទិញសំរាប់នាំចេញទៅប្រទេសចិន ។

# ជំពូកទី ៥. អនុសាសន៍ផ្នែកគោលនយោបាយ និងសេចក្តីសន្និដ្ឋាន

## ៥.១. សំរាប់ជ័រកៅស៊ូ

ដំណាំជ័រកៅស៊ូនៅកម្ពុជា បានរីកចម្រើនគួរឱ្យកត់សំគាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗ ដោយមានកំណើនយ៉ាងលឿននៅក្នុងផលិតកម្ម ផលិតភាព និងបរិមាណនាំចេញ ។ បរិមាណផលិតកម្មសរុបនៅទូទាំងប្រទេសនៅឆ្នាំ២០០៦ បានស្មើនឹង ២,១៩លានតោន ដោយមានផលិតភាពជាមធ្យម ២២,៧តោនក្នុងមួយហិកតា ។ ចំណាយផលិតកម្មប្រែប្រួលជាខ្លាំងទៅតាមខេត្តនានា ទៅតាមស្ថានភាពភូមិសាស្ត្រ និងរបៀបដាំដុះ (៤៦៤,៨ដុល្លារអាមេរិកក្នុងមួយហិកតា នៅខេត្តបាត់ដំបង និង ៣២៩,១ដុល្លារអាមេរិក នៅខេត្តកំពង់ចាម) ប៉ុន្តែប្រាក់ចំណេញរបស់កសិករមិនខុសគ្នាច្រើនទេ ដោយជាមធ្យមកសិករទទួលបានប្រាក់ចំណេញ ៣៤០ដុល្លារអាមេរិកក្នុងមួយហិកតា ។

មានស្ថិតិពាណិជ្ជកម្មជាច្រើនបង្ហាញថា កម្ពុជាបាននាំចេញបរិមាណជ័រកៅស៊ូតិចតួច ទៅកាន់ទីផ្សារមួយចំនួនតូច ជាពិសេសទៅទីផ្សារនៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសម៉ាឡេស៊ី ក៏ពិតមែន ប៉ុន្តែមានការនាំចេញជ័រកៅស៊ូយ៉ាងច្រើន តាមរយៈពាណិជ្ជកម្មឆ្លងដែនមិនផ្លូវការទៅកាន់ប្រទេសវៀតណាម និងប្រទេសថៃ ហើយលំហូរនេះពុំមានកត់ត្រាត្រឹមត្រូវនៅក្នុងស្ថិតិពាណិជ្ជកម្មផ្លូវការឡើយ ។ គេនាំចេញជ័រកៅស៊ូស្រស់ ឬចំណិតជ័រកៅស៊ូស្ងួត ដោយគ្មានឆ្លងកាត់ដំណាក់កាលកែច្នៃអ្វីទៀតទេ ។ មានសហគ្រាសមួយចំនួនតូច ដែលធ្វើការកែច្នៃជ័រកៅស៊ូហើយនាំចេញ ប៉ុន្តែតម្លៃបន្ថែមមានកម្រិតទាបនៅក្នុងខ្សែរយៈកំណត់តម្លៃជ័រកៅស៊ូនេះ ។

នៅក្នុង DTIS ឆ្នាំ២០០៧ ជ័រកៅស៊ូត្រូវបានកំណត់ជាដំណាំនាំចេញមានសក្តានុពលនាំចេញក៏រិតខ្ពស់ និងមានឥទ្ធិពលច្រើនណាស់លើការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ដោយសារជាសំខាន់ប្រទេសកម្ពុជាមានសមត្ថភាពច្រើនក្នុងការដាំជ័រកៅស៊ូ ដូចគ្នានឹងប្រទេសដទៃនៅក្នុងតំបន់ដែរ (ចំណាយផលិត និងផលិតភាព មានកម្រិតប្រហាក់ប្រហែលនឹងប្រទេសវៀតណាម និងប្រទេសថៃ) ហើយតម្រូវការជ័រកៅស៊ូនៅលើពិភពលោកកំពុងមាននិន្នាការកើនឡើង ។ ចំពោះលទ្ធភាពចូលទីផ្សារវិញ ប្រទេសជាច្រើន រួមមាន សមាជិកអាស៊ាន សហភាពអឺរ៉ុប និងប្រទេសចិន បានផ្តល់អត្រាពន្ធអនុគ្រោះពន្ធដល់ជ័រកៅស៊ូនាំចេញរបស់កម្ពុជា ស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីប្រចាំតំបន់ ពោលគឺ AFTA ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ឬ កម្មវិធី GSP របស់ប្រទេសអភិវឌ្ឍន៍សំរាប់បណ្តាប្រទេសលូតលាស់តិចជាងគេ ។ ចំណុចទាំងនេះ បានក្លាយជាកត្តាជម្រុញឱ្យកម្ពុជាអភិវឌ្ឍផលិតកម្មជ័រកៅស៊ូ និងលើកកំពស់ការនាំចេញជ័រកៅស៊ូដែលមានតម្លៃបន្ថែមកាន់តែច្រើន ។

ជាក់ស្តែងគេឃើញមានកំហិត និងបញ្ហាប្រឈមធ្ងន់ធ្ងរមួយចំនួន ដែលបង្កឧបសគ្គដល់កម្ពុជាក្នុងការសម្រេចបានពេញលេញនូវសក្តានុពលជ័រកៅស៊ូ និងដែលមានជាសង្ខេបដូចខាងក្រោម:

*គ្មានគោលនយោបាយច្បាស់លាស់ និងគ្មានក្របខ័ណ្ឌស្ថាប័ន:* ខណៈដែលប្រទេសកម្ពុជាបានកសាងរចនាសម្ព័ន្ធជាមូលដ្ឋានសំរាប់ការអភិវឌ្ឍ គេមិនឃើញមានក្របខណ្ឌគោលនយោបាយអ្វីមួយច្បាស់លាស់ទេ សំរាប់ការអភិវឌ្ឍកសិកម្ម និងការអភិវឌ្ឍជនបទ (RGC, 2001 & 2006) ។ យុទ្ធសាស្ត្រវិនិយោគសំរាប់ការអភិវឌ្ឍប្រព័ន្ធផលិតកម្ម ឈរលើមូលដ្ឋានធនធាន និងបច្ចេកវិទ្យា រាប់ទាំងកសិ-ឧស្សាហកម្មផងដែរ មិនទាន់កសាងបាននៅឡើយទេ ។ គេមិនឃើញមាន

ក្របខណ្ឌគតិយុត្តអ៊ីរ៉ឹងប៉ឹង ហើយក៏មិនឃើញមានបទបញ្ញត្តិណែនាំអ្វីច្បាស់លាស់ សំរាប់គ្រប់គ្រងការបែងចែកការការពារ និងការគ្រប់គ្រងធនធានឡើយ ។ ម្យ៉ាងទៀតការបកស្រាយ និងការអនុវត្តបទបញ្ញត្តិនានា មានលក្ខណៈមិនស៊ីសង្វាក់គ្នា និងមិនអាចប៉ាន់ប្រមាណជាមុនបាន ហើយនីតិវិធីនាំចេញមានលក្ខណៈស្មុគស្មាញ និងបង្កបញ្ហាច្រើន (World Bank, 2004) ។ ខណៈដែលការនាំចេញដំឡូងឈើត្រូវគោរពតាមលក្ខខណ្ឌអនាម័យរបស់ប្រទេសនាំចូល ការទទួលសេចក្តីបញ្ជាក់ដែលគេហៅថា វិញ្ញាបនប័ត្រអនាម័យ និងភូត្គាមអនាម័យ (SPS certificate) ត្រូវការពេលវេលាច្រើន មានចំណាយខ្ពស់ ហើយបង្កនូវដំណើរការលំបាកដល់សហគ្រាសនានា ដោយសារតែសមត្ថភាព និងមធ្យោបាយមានកម្រិតរបស់បណ្តាស្ថាប័នទទួលបន្ទុក និងជួយគាំទ្រ ។

*ឧបសគ្គផ្នែកស្ថាប័ន និងឧបសគ្គផ្នែកហិរញ្ញវត្ថុ៖* គេឃើញមានការខ្វះចន្លោះ និងភាពត្រួតគ្នានៃអាណត្តិការងាររបស់បណ្តាស្ថាប័នដែលគាំទ្រការអភិវឌ្ឍកសិកម្ម និងអភិវឌ្ឍជនបទ ។ គ្រឹះស្ថានសាធារណៈ ក៏ត្រូវប្រឈមមុខផងដែរនឹងកង្វះធនធានមនុស្សមានជំនាញបច្ចេកទេស កង្វះធនធានហិរញ្ញវត្ថុសំរាប់អនុវត្តផែនការអភិវឌ្ឍកសិកម្ម និងកង្វះមូលដ្ឋានសម្ភារៈសំរាប់ធ្វើការស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម ។

*សេវាផ្សព្វផ្សាយកសិកម្មមិនគ្រប់គ្រាន់៖* ការចាត់ចែង និងយន្តការ សំរាប់ផ្តល់សេវាគាំទ្រកសិកម្ម ដូចជា កម្មវិធីផ្សព្វផ្សាយជាដើម សព្វថ្ងៃពុំឃើញមាន ឬមានមិនគ្រប់គ្រាន់ទេ (RGC, 2001 & 2006) ។ មានការទទួលស្គាល់ជាទូទៅថា សេវាផ្សព្វផ្សាយកសិកម្មមានលក្ខណៈអន់ខ្សោយណាស់ ហើយប្រព័ន្ធមួយដែលមានដំណើរការពេញលេញសំរាប់ផ្តល់សេវាគាំទ្រ ជាពិសេសធ្វើការផ្សព្វផ្សាយបច្ចេកទេសទៅដល់ប្រជាពលរដ្ឋនៅជនបទ គឺមិនទាន់បង្កើតបាននៅឡើយទេ ។ បច្ចុប្បន្ន គេផ្សព្វផ្សាយព័ត៌មានបច្ចេកទេសជាសំខាន់តាមបណ្តាញក្រៅផ្លូវការ រួមមាន ការផ្សព្វផ្សាយតាមរយៈកសិករ អ្នកនៅជិតខាង អង្គការមិនមែនរដ្ឋាភិបាល អ្នកបច្ចេកទេសកសិកម្ម និងអ្នកចែកចាយកត្តាផលិតកម្មកសិកម្ម ។ កសិករមានលទ្ធភាពតិចតួចណាស់ ដើម្បីទទួលបានបច្ចេកវិទ្យាល្អៗ ព្រោះថា សេវាផ្សព្វផ្សាយកសិកម្មគ្មានការគាំទ្រដោយការស្រាវជ្រាវ និងអភិវឌ្ឍន៍ឡើយ ។ ស្ថាប័នរដ្ឋគ្មានលទ្ធភាពផ្តល់សេវា និងមុខងារសំខាន់ៗឱ្យបានទាន់ពេលវេលា ដើម្បីគាំទ្រដល់ការធ្វើកសិកម្មដែលមានផលិតភាពល្អ មានលក្ខណៈអតិផល និងមានច្រើនមុខច្រើនបែប ។

*អវត្តមានប្រព័ន្ធទីផ្សារដ៏មានប្រសិទ្ធភាព៖* យន្តការទីផ្សារ សំរាប់សម្រួលការដឹកជញ្ជូនផលិតផលកសិកម្មពីកសិករទៅដល់អ្នកប្រើប្រាស់ចុងក្រោយ (ទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ) មានដំណើរការមិនល្អទេ (Hing & Nou, 2006) ។ កសិករហាក់ដូចមានកម្លាំងចរចាតិចជាងឈ្មួញកណ្តាល ដោយផលិតផលរបស់ពួកគេ ត្រូវបានកំណត់ថ្លៃទាបជាខ្លាំងជាងកម្រិតដែលគួរទទួលបាន ប្រសិនបើមានការប្រកួតប្រជែងទីផ្សារត្រឹមត្រូវ ។ នាបច្ចុប្បន្ន ស្ថាប័នជាតិផ្នែកទីផ្សារពុំទាន់មាននៅឡើយទេ គឺមានតែសេវាព័ត៌មានទីផ្សារ អនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមជំនួយរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO) ប៉ុណ្ណោះ ដែលកំពុងធ្វើការអភិវឌ្ឍទីផ្សារ ។

*ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ៖* កង្វះហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដូចជាប្រព័ន្ធស្រោចស្រព ផ្លូវថ្នល់ និងការដឹកជញ្ជូន គឺជាឧបសគ្គចំបងដល់ការបង្កើនផលិតភាពកសិកម្ម ការជួយសម្រួលលំហូរពាណិជ្ជកម្ម និងលទ្ធភាពទាក់ទងបានងាយស្រួលទៅកាន់មណ្ឌលផលិតកម្ម ។ ប្រការនេះធ្វើឱ្យមានចំណាយប្រតិបត្តិការខ្ពស់ លទ្ធភាពមិនស្មើគ្នាក្នុងចំណោមរោងចក្រកែច្នៃនៅតំបន់ទីក្រុង ក្នុងការទាក់ទងទៅកាន់មូលដ្ឋានផលិតកម្ម និងឈ្មួញបរទេសនៅជិតខាង និងវត្តមានពាណិជ្ជកម្មឆ្លងដែនក្រៅផ្លូវការច្រើន ដែលផ្តល់តម្លៃបន្ថែមបានតិច ។

រដ្ឋាភិបាលបានទទួលស្គាល់យ៉ាងច្បាស់នូវបញ្ហាប្រឈមទាំងនេះ ដូចមានបញ្ជាក់ក្នុងផែនការអភិវឌ្ឍនសេដ្ឋកិច្ច-សង្គមកិច្ចនានា (SEDP I, SEDP II, NSDP) ក៏ដូចជាយុទ្ធសាស្ត្រពាណិជ្ជកម្ម ។ គោលនយោបាយទាំងនោះ ក៏បានលើកនូវសំណើសកម្មភាពគោលនយោបាយអាទិភាព និងយុទ្ធសាស្ត្រច្បាស់លាស់ សំដៅអភិវឌ្ឍវិស័យកសិកម្ម និងលើកកំពស់

កសិកម្ម ក្នុងបរិបទនៃប្រព័ន្ធពាណិជ្ជកម្មក្នុងតំបន់ និងក្នុងពិភពលោក ។ ទាក់ទិននឹងការលើកកំពស់វិស័យកសិកម្មរបៀបវារៈអាទិភាព រួមមាន ការកសាងយុទ្ធសាស្ត្រតាមវិស័យគ្រប់ជ្រុងជ្រោយសំរាប់កសិកម្ម ការបង្កើនវិនិយោគសាធារណៈក្នុងវិស័យនេះ ការលើកទឹកចិត្តនិងការជួយសម្រួល ការចូលរួមរបស់ផ្នែកឯកជនក្នុងវិស័យកសិកម្ម និងការកែច្នៃផលិតផលកសិកម្ម ការពង្រីកសេវាផ្សព្វផ្សាយ និងការកែលំអហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ។ ទាក់ទិននឹងការអភិវឌ្ឍការនាំចេញផ្នែកកសិកម្ម សកម្មភាពអាទិភាព រួមមាន ការកែលំអលទ្ធភាពចូលទីផ្សារ និងបង្កើនផលចំណេញជាអតិបរមាពីពាណិជ្ជកម្មដែលមានលក្ខខណ្ឌអនុគ្រោះ កិច្ចសម្រួលពាណិជ្ជកម្មកាន់តែប្រសើរ និងការកសាងក្របខណ្ឌបទបញ្ញត្តិច្បាប់ និងសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តគោលនយោបាយពាណិជ្ជកម្មឱ្យបានល្អប្រសើរ ។

បទពិសោធន៍កន្លងមកបង្ហាញថា រដ្ឋាភិបាលមានគោលនយោបាយល្អ និងពេញលេញ ផ្តោតចំបញ្ហាសំខាន់ៗ ប៉ុន្តែបានយកចិត្តទុកដាក់តិចតួចលើបញ្ហាអនុវត្ត ។ ទោះបីរដ្ឋាភិបាលបានជឿនលឿនទៅមុខច្រើនហើយ ក្នុងការអនុវត្តសកម្មភាពជាអាទិភាព និងកម្មវិធីកំណែទម្រង់ផ្សេងៗ ប៉ុន្តែគេអាចទទួលបានលទ្ធផលល្អថែមទៀត ប្រសិនបើគោលនយោបាយទាំងនោះត្រូវបានអនុវត្តកាន់តែមានប្រសិទ្ធិភាព ។ នៅក្នុងបរិបទនេះ គួរមានពេលវេលាសមស្របសំរាប់ឱ្យរដ្ឋាភិបាលអាចយកចិត្តទុកដាក់បានកាន់តែខ្លាំងដល់ប្រសិទ្ធិភាពនៃការអនុវត្តគោលនយោបាយ ក្នុងនេះមានសមាសធាតុបី ដែលរដ្ឋាភិបាលគួរពិចារណា ដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាព ។

*ភាពជាអ្នកដឹកនាំរឹងមាំ:* នេះជាសមាសធាតុសំខាន់មួយ ដើម្បីឱ្យការពង្រឹងអនុវត្តបទបញ្ញត្តិ និងកម្មវិធីកំណែទម្រង់ទទួលបានជោគជ័យ ជាពិសេសសំរាប់បរិបទនយោបាយ និងសេដ្ឋកិច្ចនៅកម្ពុជា ។

*ក្របខណ្ឌស្ថាប័នច្បាស់លាស់:* គប្បីមានគោលការណ៍ណែនាំច្បាស់លាស់អំពីអាណត្តិការងារ និងការទទួលខុសត្រូវនៃស្ថាប័នពាក់ព័ន្ធក្នុងការជួយគាំទ្រ និងសម្របសម្រួលការអនុវត្តគោលនយោបាយ ។

*ធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់:* ការប្រមែប្រមូលធនធានត្រូវតែពង្រឹងឡើង នៅក្នុងដំណើរការអនុវត្តគោលនយោបាយ ។ កិច្ចការនេះអាចអនុវត្តតាមរយៈការបង្កើនថវិការបស់រដ្ឋាភិបាល ឬការស្វែងរកជំនួយអភិវឌ្ឍន៍បន្ថែមពីសហគមន៍អ្នកផ្តល់ជំនួយ ។

## ៥.២. សំរាប់ជំឡូងឈើ

ដំឡូងឈើមានសក្តានុពលល្អសំរាប់ការពង្រីកផលិតកម្ម និងការនាំចេញ ដែលនឹងជួយបង្កើនប្រាក់ចំណូលរបស់កសិករ និងកែលំអការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ។ សក្តានុពលនៃដំណាំដំឡូងឈើអាចសម្រេចបានពេញលេញ លុះត្រាតែមានគោលនយោបាយច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដែលអាចដោះស្រាយឧបសគ្គ និងបញ្ហាប្រឈមចំបងៗ ព្រមទាំងមានភាពជាអ្នកដឹកនាំច្បាស់លាស់ និងស្ថាប័នមានសមត្ថភាព ដើម្បីអនុវត្តយុទ្ធសាស្ត្រនានាឱ្យកាន់តែមានប្រសិទ្ធភាព ។

### សំរាប់ដំណាំកៅស៊ូ

ឧស្សាហកម្មកៅស៊ូកម្ពុជាត្រូវបានកំណត់នៅក្នុងឯកសារ DTIS 2007 ថាជាវិស័យមួយមានសក្តានុពលនាំចេញខ្ពស់ ។ ស្ថានភាពផ្គត់ផ្គង់ក្នុងស្រុកទទួលបានចំណាត់ថ្នាក់ខ្ពស់លើចំណុចខ្លាំង និងឱកាសល្អ ដូចតទៅៈ កៅស៊ូស្រស់មានគុណភាពអាចប្រៀបធៀបជាមួយគេបាន កម្ពុជាមានសក្តានុពលខ្ពស់ក្នុងការពង្រីកផ្ទៃដីដាំដុះ មានសក្តានុពលក្នុងការអភិវឌ្ឍនៅពេលអនាគត នូវតម្លៃបន្ថែមនៃឧស្សាហកម្មកៅស៊ូ និងមាននិន្នាការឈានទៅធ្វើឯកជនភាវូបនីយកម្មពេញលេញ នូវសហគ្រាសរបស់រដ្ឋ (MoC, 2007) ។ ទោះបីជាមានការកំណត់សកម្មភាពអាទិភាពនៅក្នុងឯកសារ DTIS 2007 ក្តី ក៏ការសិក្សាបាន

លើកជាអនុសាសន៍ខាងគោលនយោបាយមួយចំនួនដូចតទៅនេះ ដើម្បីព្យាយាមដោះស្រាយបញ្ហាធ្ងន់ធ្ងរ និងបញ្ហាប្រឈមនានាដែលកសិករដំណាំកៅស៊ូ និងអ្នកនាំចេញកំពុងជួបប្រទះ ។

បញ្ហាចំបងមួយដែលការសិក្សានេះ ក៏ដូចជាឯកសារបោះផ្សាយពាក់ព័ន្ធមួយចំនួនទៀតបានរកឃើញ[១១] គឺ ជាប់ពាក់ព័ន្ធនឹងផលិតភាព ។ ទិន្នផលមធ្យមនៃកៅស៊ូនៅកម្ពុជាមានកម្រិតទាប ធៀបនឹងប្រទេសផលិតកៅស៊ូធំៗនៅក្នុងតំបន់ ដោយសារជាសំខាន់ វត្តមានដើមកៅស៊ូមានអាយុចាស់ជាង ២៥ឆ្នាំ និងការប្រើប្រាស់ពូជមានទិន្នផលទាប ។ កសិករកៅស៊ូលក្ខណៈគ្រួសារ ច្រើនប្រើពូជផ្តល់ទិន្នផលទាប ។ ការសិក្សានេះបង្ហាញថា កសិករដំណាំកៅស៊ូគ្រួសារប្រហែលពាក់កណ្តាលពុំមានទុនគ្រប់គ្រាន់សំរាប់ទិញពូជកៅស៊ូទេ ហើយពួកគេប្រើពូជចម្រុះដែលប្រមូលពីចំការដទៃ ។ ការអនុវត្តបែបនេះជួយកាត់បន្ថយចំណាយ ប៉ុន្តែក៏ផ្តល់ទិន្នផលទាបដែរ ។

